# ធនាគារជាតិ នៃ កម្ពុជា

# ព្រឹត្តិបត្រប្រចាំត្រីមាស




## លេខ ១

## ត្រីមាសទី៣ ឆ្នាំ២០០២

ចេញផ្សាយតាមប្រកាសលេខ ធ១-០២-១២៦ ប្រ.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២

# មាតិកា


~ អារម្ភកថា

~ ប្រវត្តិនៃការអភិវឌ្ឍន៍ប្រព័ន្ធធនាគារនៅកម្ពុជា ១-១០

~ ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ១១

~ ការអនុវត្តន៍បេសកកម្មរបស់ធនាគារជាតិនៃកម្ពុជា ១២-១៥

~ ប្រព័ន្ធធនាគារនៅកម្ពុជា  និងដុល្លារូបនីយកម្ម ១៦-២៤

~ បញ្ជីឈ្មោះធនាគារពាណិជ្ជ ២៥-២៨

~ រចនាសម្ព័ន្ធប្រព័ន្ធធនាគារនៅកម្ពុជា ២៩-៣២

~ ពីអត្រាប្តូរប្រាក់ថេរទៅអត្រាប្តូរប្រាក់អណ្តែត ៣៣-៣៥

~ ការរួមចំណែករបស់ធនាគារជាតិនៃកម្ពុជាក្នុងការងារកែទំរង់ប្រព័ន្ធពន្ធដារ ៣៦-៣៨

~ ទំនាក់ទំនងហិរញ្ញវត្ថុរវាងប្រទេសកម្ពុជានិងមូលនិធិរូបិយវត្ថុអន្តរជាតិ ៣៩-៤១

~ ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ៤២-៤៩

~ សហប្រតិបត្តិការអន្តរជាតិទ្វេភាគី ៥០

~ សកម្មភាពសង្គមកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ៥១-៥៤

~ ចំណុចសំគាល់មួយចំនួនស្តីពីប្រាក់ដុល្លារក្លែងក្លាយ ៥៥-៥៨

# អារម្ភកថា



ឯកឧត្តម ជា ចាន់តូ
ទេសាភិបាលធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាគឺជាធនាគារកណ្តាលរបស់ប្រទេសដែលជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជាដំណើរការនៅក្រោមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា (ច្បាប់ធនាគារកណ្តាល) ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ។ ច្បាប់នេះ គឺជាជំហានដ៏សំខាន់ក្នុងការធ្វើកំណែទំរង់ធនាគារកណ្តាលតាមរយៈការផ្តល់នូវលក្ខន្តិកៈច្បាស់លាស់ចំពោះធនាគារជាតិនៃកម្ពុជា ព្រមទាំងការក្រាលនូវមូលដ្ឋានគ្រឹះសំរាប់ ប្រតិបត្តិការនៃធនាគារកណ្តាលផងដែរ ។ ដូចមានចែងក្នុងច្បាប់ ធនាគារជាតិនៃកម្ពុជាមានបេសសកកម្មចំបង គឺកំណត់និងដឹកនាំនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាថ្លៃឱ្យមានស្ថេរភាពសំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចំរើន ។

ដើម្បីជំរុញការអនុវត្តន៍គោលដៅខាងលើ ក្នុងរយៈពេលកន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានខិតខំទៅតាមសមត្ថភាពធនធានមនុស្សដែលមាន ប្រមូលផ្តុំទិន្នន័យនិងចេញផ្សាយស្ថិតិអំពីរូបិយវត្ថុនិងធនាគារ និងស្ថិតិបន្ទាប់បន្សំទាំងឡាយដូចជា ស្ថិតិទាក់ទិននឹងឥណទាននិងប្រាក់បញ្ញើ អត្រាការប្រាក់ ស្ថិតិស្តីពីថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងជញ្ជីងទូទាត់ជាដើម នៅក្នុងព្រឹត្តប័ត្រស្ថិតិសេដ្ឋកិច្ចនិងរូបិយវត្ថុ ដើម្បីផ្តល់ពត៌មានបច្ចុប្បន្ន ប្រចាំខែពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចជារួមចំពោះសាធារណជន ។

ទោះជាយ៉ាងនេះក្តី ក្នុងស្មារតីបំពេញតាមសំណូមពរចាំបាច់ដែលមានចែងនៅក្នុងច្បាប់ធនាគារកណ្តាល ឆ្នាំ១៩៩៩ ធនាគារជាតិនៃកម្ពុជាសំរេចរៀបចំព្រឹត្តិបត្រថ្មីមួយទៀតដែលមានឈ្មោះថា "ព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជា" ។ ព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជា មានបំណងបីយ៉ាងជាសំខាន់គឺ:

១. រួមចំណែកបង្កើនការយល់ដឹងលើទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយរូបិយវត្ថុ ព្រមទាំងទិដ្ឋភាពនៃកំណែទំរង់ និងការអភិវឌ្ឍន៍ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ ។ល។ ចំពោះសាធារណជន អ្នកវិនិយោគ ព្រមទាំងអ្នកប្រើប្រាស់ពត៌មានពីវិស័យធនាគារ និងហិរញ្ញវត្ថុទាំ ងឡាយ រួមទាំងនិស្សិតនិងអ្នកសិក្សាស្រាវជ្រាវផ្សេងៗ ។

២. បង្កើនតម្លាភាពនៅក្នុងការអនុវត្តន៍នយោបាយរូបិយវត្ថុ និងនយោបាយពង្រឹងប្រព័ន្ធធនាគាររបស់ធនាគារកណ្តាល ដែលនឹងរួមចំណែកបង្កើនទំនុកចិត្តរបស់សាធារណជនមកលើគោលនយោបាយរបស់រដ្ឋាភិបាល និងលើវិស័យធនាគារ ។

៣. បំរើជាមធ្យោបាយសំរាប់ជំរុញឱ្យមានមតិយោបល់ ជាការឆ្លើយតបមកវិញពីសំណាក់ភាគីមាន

ចំណាប់អារម្មណ៍ទាំងឡាយ ចំពោះដំណើរការអភិវឌ្ឍន៍វិស័យធនាគារនិងហិរញ្ញវត្ថុ នៅក្នុងស្មារតីផ្តោះប្តូរមតិដើម្បីស្ថាបនា ។

ព្រឹត្តិបត្រធនាគារជាតិនៃកម្ពុជាពុំមែនបង្កើតឡើងដើម្បីជំនួសឱ្យពត៌មានស្ថិតិនិងរូបិយវត្ថុទេ តែជាការងារបន្ថែម ដើម្បីបំពេញនូវកង្វះខាតពត៌មានលើវិស័យធនាគារ និងហិរញ្ញវត្ថុ ។ ដូច្នេះ នៅពេលដែលពត៌មានសេដ្ឋកិច្ច ស្ថិតិ និងរូបិយវត្ថុ បង្ហាញពីតារាងទិន្នន័យ ព្រមទាំងក្រាហ្វស្ថិតិ ដោយមានបទអត្ថាធិប្បាយបច្ចេកទេសសង្ខេបជាការពន្យល់ទៅលើទិន្នន័យ ហើយត្រូវចេញផ្សាយជារៀងរាល់ខែនោះ ព្រឹត្តិបត្រថ្មីនេះនឹងផ្សព្វផ្សាយនូវគោលនយោបាយ បទអត្ថាធិប្បាយពីលទ្ធផលនៃកំណែទំរង់ប្រព័ន្ធធនាគារ អត្ថបទសិក្សាស្រាវជ្រាវផ្សេងៗ ។ល។ ហើយនឹងត្រូវរៀបចំឱ្យចេញផ្សាយប្រចាំត្រីមាស ។

ធនាគារជាតិនៃកម្ពុជាសង្ឃឹមថា ព្រឹត្តិបត្រថ្មីនេះនឹងដើរតួនាទីយ៉ាងល្អក្នុងការបំពេញតំរូវការរបស់ភាគីមានចំណាប់អារម្មណ៍ទាំងឡាយ លើពត៌មានដែលមានប្រយោជន៍ចំពោះគេ ។ ទន្ទឹមនោះដែរ ធនាគារជាតិនៃកម្ពុជាសង្ឃឹមយ៉ាងមាំថា នឹងបានទទួលត្រឡប់មកវិញពីអ្នកអានទាំងឡាយនូវមតិយោបល់ល្អៗដើម្បីធ្វើឱ្យព្រឹត្តិបត្រនេះកាន់តែមានលក្ខណៈប្រសើរឡើងថែមទៀត ។

ទេសាភិបាល

ជា ចាន់តូ

## ប្រវត្តិនៃការអភិវឌ្ឍន៍ប្រព័ន្ធធនាគារនៅកម្ពុជា

ធនាគារជាតិនៃកម្ពុជា ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ បន្ទាប់ពីវិជ្ជាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ គឺនៅពេលដែលប្រទេសទាំងបី កម្ពុជា វៀតណាម និងឡាវ ដណ្តើមបានឯករាជ្យរៀង១ខ្លួនពីអាណានិគមនិយមបារាំង ។ ក្នុងដំណាក់កាលដំបូងនោះ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយប្រាក់រៀលឯករាជ្យមួយ ដើម្បីបញ្ចប់ជាស្ថាពរនូវសម្ព័ន្ធភាពជាមួយប្រាក់វៀតណាម និងលាវ ។




ក្រដាសប្រាក់រៀលបោះពុម្ពដោយធនាគារជាតិនៃកម្ពុជាជាលើកដំបូងបន្ទាប់ពីទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង

After the **Indochina Bank Note Printing Institute** was closed down, the National Bank of Cambodia was established on December 23, 1954 when the three Indochina countries, Cambodia, Vietnam and Laos, gained independence from France. In the initial stage, to permanently terminate its alliance of a joint currency with Vietnam and Laos, the National Bank of Cambodia issued independent Khmer Riel banknotes.

ចាប់តាំងពីការកកើតដំបូងរហូតដល់ឆ្នាំ១៩៧០ធនាគារជាតិនៃកម្ពុជាបានបំរើយ៉ាងជិតស្និទ្ធដល់គោលនយោបាយកសាងជាតិនៃសង្គមរាស្ត្រនិយម ។ ក្នុងកំឡុងពេលនោះ ធនាគារជាតិមានការប្រែប្រួលជាសំខាន់នៅក្នុងឆ្នាំ១៩៦៤ ។ ធនាគារជាតិនៃកម្ពុជា បានប្រែក្លាយពីទម្រង់ជាស្ថាប័នពាក់កណ្តាលស្វ័យតទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈដែលមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្ម ។ នាពេលនោះ ធនាគារឯកជន ជាតិនិងបរទេសដែលកំពុងធ្វើប្រតិបត្តិការត្រូវបានបិទទ្វារ ត្រូវបានបង្កើតជាធនាគារដែលរដ្ឋកាន់កាប់

រួមមានធនាគារខ្មែរសំរាប់ពាណិជ្ជកម្ម ធនាគារឥណទានជាតិ ធនាគារអភិវឌ្ឍន៍ និងធនាគារកសិកម្មជនបទ ។ ទន្ទឹមនឹងនោះដែរ មន្ទីររាជសហករណ៍ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៦ ត្រូវបានរៀបចំនិងគ្រប់គ្រងសហករណ៍បីគឺ សហករណ៍ផលិតកម្ម សហករណ៍ឧបភោគបរិភោគ និងសហករណ៍ឥណទាន ។ សហករណ៍ឥណទានបានធ្វើសកម្មភាពឥណទានយ៉ាងទូលំទូលាយទូទាំងប្រទេសនៅក្រៅប្រព័ន្ធធនាគារ ដើម្បីគាំទ្រដល់ប្រជារាស្ត្រតូចតាច ។ សកម្មភាពឥណទាននេះ ជាសំខាន់ត្រូវបានបង្កើតឡើងមុនការបង្កើតធនាគារកសិកម្មជនបទនាឆ្នាំ១៩៧០ ។

ចាប់ពីចុងឆ្នាំ ១៩៧០ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ប្រព័ន្ធធនាគារបានធ្វើសេរីភាវូបនីយកម្មជាថ្មី ដើម្បីបង្កលក្ខណៈឱ្យធនាគារឯកជនធ្វើសកម្មភាពទន្ទឹមនឹងធនាគាររដ្ឋទាំងឡាយ ក្រោមការបញ្ជាណែនាំ និងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។ តែជាអកុសល នៅក្នុងរបប ប៉ុល ពត (ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ ខែមករា ឆ្នាំ១៩៧៩) ប្រព័ន្ធធនាគារត្រូវបានទទួលរងការបំផ្លិចបំផ្លាញទាំងស្រុង ប្រាក់រៀលក៏ត្រូវបានបោះបង់ចោល ហើយសូម្បីតែអគារធនាគារជាតិនៃកម្ពុជាក៏ត្រូវបានកំទេចចោលទាំងស្រុងដែរ ។



ក្រដាសប្រាក់រៀលសម័យសង្គមរាស្ត្រនិយម បោះពុម្ពដោយធនាគារជាតិនៃកម្ពុជា

The National Bank of Cambodia closely served the Sangkum Reas Niyum national construction policy from the date it was established to 1970. In the meantime, the National Bank of Cambodia changed significantly in 1964, being transformed from a semi autonomous into a state bank with the form of a public entity of a commercial and industrial nature. At that time, local and foreign private banks in operation were shut down and reestablished as state-owned banks, consisting of the Khmer Bank for Commerce, the National Credit Bank, the Development Bank and the Rural Agriculture Bank. Similarly, the **Royal Cooperative Department** established in 1956, was

organized and took 3 cooperatives under its control, including Production, Food Supply and Credit Cooperatives. The operational activities of the Credit Cooperative were extended, beyond the banking system, to every area across the country, aimed at supporting the poor. The implementation of those significant activities had started prior to the establishment of the Rural Agriculture Bank in 1970.

From late 1970 to January 1975, the banking system was liberalized once again in order to ensure that private banks could operate under the National Bank of Cambodia's supervision and regulation as other state banks did. Unfortunately, during Pol Pot regime from April 1975 to January 1979, the banking system was totally destroyed, the Riel banknotes were abandoned and, additionally, the National Bank of Cambodia building was fully destroyed.

### ដំណាក់កាលជាង២០ឆ្នាំ ក្រោយឆ្នាំ១៩៧៩

ធនាគារជាតិនៃកម្ពុជា ត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ។ ក្នុងដំណាក់កាលជាង២០ឆ្នាំចុងក្រោយនេះ គេអាចចែកប្រវត្តិស្ថាប័នរូបិយវត្ថុកម្ពុជាជាពីរ ដំណាក់កាលតូចៗគឺ ដំណាក់កាលឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ និងដំណាក់កាលក្រោយឆ្នាំ១៩៩៣ ។

The National Bank of Cambodia (NBC) was re-established on October 10, 1979. In this more than 20-years stage, the history of the Cambodia monetary institution can be divided into two different stages, from 1979 to 1993, and after 1993.



ក្រដាសប្រាក់រៀលបោះពុម្ពដោយធនាគារជាតិនៃប្រជាជនកម្ពុជាក្នុងអំឡុង ឆ្នាំ១៩៨០-១៩៨៨

**ដំណាក់កាលពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣**

ក្នុងដំណាក់កាលនេះ ប្រវត្តិស្ថាប័នរូបិយវត្ថុកម្ពុជាត្រូវបានកត់ត្រានូវវីរភាពដ៏ថ្លៃថ្លា ការលះបង់ដ៏ខ្ពស់បំផុត និងការសំរេចលទ្ធផលគួរជាទីមោទនៈ ។ ប្រការទាំងនេះបានសំដែងឡើងតាមរយៈការបង្កើតធនាគារកណ្តាល ការបោះផ្សាយប្រាក់រៀលឡើងវិញ និងការរួមចំណែកស្តារជីវភាពសង្គ្រោះប្រជាជាតិឱ្យរួចផុតពីគ្រោះទុរ្ភិក្ស ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ។ ភាពដ៏អស្ចារ្យទាំងនោះគឺ :

ទី១- ក្នុងរយៈពេលតែ ១០ខែ ក្រោយថ្ងៃរំដោះ ធនាគារជាតិនៃប្រជាជនកម្ពុជាត្រូវបានបង្កើតឡើង ហើយបន្ទាប់មកប្រាក់រៀលក៏ត្រូវបានបោះផ្សាយដើម្បីជួយឱ្យជីវភាពសង្គមវិលមករកប្រក្រតីភាពវិញ ។

ទី២-ធនាគារជាតិនៃប្រជាជនកម្ពុជាបានរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីនដឹកនាំ និងសកម្មភាពប្រតិបត្តិការនៅទីស្នាក់ការកណ្តាលរបស់ខ្លួន ហើយបានពង្រីកបណ្តាញទៅបណ្តាខេត្ត-ក្រុងទាំង២០យ៉ាងឆាប់រហ័សបំផុត ។ ភាពដ៏អស្ចារ្យនេះស្ថិតនៅលើចំណុចដែលគួរឱ្យកត់សំគាល់នោះគឺ :

- បង្កើតធនាគារមួយពីចំណុចសូន្យដោយបាតដៃទទេ ។ ទោះបីជាអគារធនាគារក្រហមត្រូវបានកំទេចឱ្យរលាយជាផេះផង់ក៏ដោយ ក៏ទីស្នាក់ការកណ្តាលត្រូវបានបើកជាបណ្តោះអាសន្ននៅលើអគារនៃអតីតធនាគារខ្មែរសំរាប់ពាណិជ្ជកម្ម ដែលមានតែសំបកអគារ ។ យើងគ្មានប្រភពហិរញ្ញវត្ថុ គ្មានសេសសល់មរតកធនាគារពីមុនមក ទាំងឯកសារ បទពិសោធន៍ និងធនធានមនុស្ស ។ អ្នកចេះដឹងត្រូវកាប់សម្លាប់ ត្រូវបែកខ្ញែកទៅគ្រប់ទិសទី ខ្លះបាក់ស្មារតីគេចវេសមិនហ៊ានចូលបំរើការងារដោយរាងចាលខ្លាចការយាយីនៃរបប ប៉ុលពតជាថ្មីទៀត ។
- ក្នុងស្ថានភាពដែលប្រជាជនកម្ពុជាមានរាងកាយស្គាំងស្គម បាក់កំលាំង សំលៀកបំពាក់រយ៉ីររយ៉ៃ ស្មារតីភ្លេចភ្លាំង គ្រួសារបែកបាក់មិនទាន់ជួបជុំគ្នា តែតាមរយៈការមូលចិត្តមូលថ្លើមធ្វើការមិនស្គាល់យប់ថ្ងៃ ការឆ្លងកាត់គ្រោះអសន្តិសុខគ្រប់ទីកន្លែង ការខំប្រឹងធ្វើការផងរៀនផងពីជំនាញការដែលផ្តល់មកតាមជំនួយដ៏ស្ហួចស្មើងនៃប្រទេសជាមិត្ត ធនាគារមួយដូចសព្វថ្ងៃនេះត្រូវបានកសាងឡើង ។

ទី៣- ដោយមានការឧបត្ថម្ភពីប្រទេសជាមិត្ត ប្រាក់រៀលថ្មីត្រូវបានបោះផ្សាយក្នុងកាលៈទេសៈដ៏សែនប្រថុចប្រថ៉ុច គឺនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០។ បើគិតទៅគឺក្នុងរយៈពេលត្រឹមតែ៦ខែក្រោយថ្ងៃបង្កើតធនាគារជាតិប៉ុណ្ណោះ ។ ការបោះផ្សាយប្រាក់រៀលនេះបានទទួលនូវការអបអរសាទរ និងគាំទ្រយ៉ាងក្លៀវក្លាបំផុតពីសំណាក់ប្រជាជន មហាជន ។ ប្រាក់រៀលបានបំរើការទូទាត់យ៉ាងឆាប់រហ័ស និងបង្កើតឡើងនូវសកម្មភាពធនាគារ និងប្រព័ន្ធចរិការដ្ឋ ។

ទី៤-ក្នុងស្ថានភាពដែលប្រទេសជាតិគ្មានប្រាក់កាសចាយវាយតាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៨០ ជាពិសេសចាប់ពីក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ រហូតដល់ខែមីនា ឆ្នាំ១៩៨០ ប្រាក់រៀលត្រូវបានបោះផ្សាយដើម្បីធ្វើចរាចរតាមរយៈការប្រើប្រាស់បៀវត្ស និងតាមរយៈឥណទាន ។

ទី៥-តាមរយៈគោលនយោបាយឥណទានចំពោះក្រុមសាមគ្គីនិងសហគ្រាសរដ្ឋ ធនាគារជាតិនៃប្រជាជនកម្ពុជាបានចូល រួមយ៉ាងមានប្រសិទ្ធភាពបំផុតក្នុងការស្តារជីវភាពរស់នៅឡើងវិញ ស្តារសភាពបាក់កំលាំង និងសង្គ្រោះ ប្រជាជាតិទាំងមូលឱ្យរួចផុតពីគ្រោះទុរ្ភិក្សក្រោយថ្ងៃរំដោះ ។ ឥណទានធនាគារបានជួយស្តារឡើងវិញនូវមុខ របរនេសាទ កសិកម្ម សិប្បកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ជាពិសេស គឺការប្រមូលទិញកសិផលដែលធ្វើឱ្យផលិតកម្មកសិកម្មបានចំរើនយ៉ាងឆាប់រហ័ស ។

**From 1979-1993**

During this period, the history of the Cambodia monetary institution recorded outstanding patriotism, height sacrifice and satisfactory results. These were pointed out through the re-establishment of the National Bank of Cambodia, the re-issuance of Riel banknotes and the participation in the rehabilitation of people living in order to save the nation from starvation after liberation day, January 7, 1979. These facs are:

- **First:** Only 10 months following the day of liberation, the National Bank of the Cambodian People was re-established and the Riel banknotes were re-issued so that the social living standards of the entire nation could quickly be normalized.

- **Second:** The National Bank of the Cambodian People set up the leadership structures and operational activities at its Head Office and extended to 20-provincial and municipal networks very rapidly. Such an achievement is noted through the following points:

  + The bank was established from scratch. Due to the destruction of the NBC building, a temporary office was opened on the upper floors of the former Khmer Bank for Commerce that left only the empty building. At that time, the National Bank of Cambodia had no financial resources, no inheritance such as documents, experience or human resources. The intellectuals were mentally scarred and dared not go to work since they feared that there would be a return of the Pol Pot regime.
  + Though living in a situation of deteriorating health, with hardly any decent clothes to wear, in a nervous state of mind and separated from family members, but through cooperatively worked days and nights, facing insecurity everywhere, and learnt from experts through a minor aide, by allied countries the bank which can be seen today was built.

**-Third:** With the support of allied countries, the new Riel banknotes were issued on 20th March 1980. Only six months after the bank was established. The Riel bank note issuance was strongly appreciated and supported by the public. The Riel banknotes swiftly served to off and create banking activity and a state budget system.

**- Fourth:** No domestic currency had been available for use as means of payments from 1975 to 1980, especially after the liberation, January 7, 1979 until March 1980. Riel banknotes were reissued and put into circulation in the country through paying salaries and extending bank credits to the economy.

**- Fifth:** Through the credit policy focusing on solidarity groups and state enterprises the People's Natinal Bank of Kampuchea (PNBK) effectively participated in restoring the standard of living, and to fight massive starvation after liberation day. The bank's credit also helped restore economic activities such as fishing, handicraft, agriculture, industry, and trade, especially allowing the purchase of agro-products in gross volume, which contributed to the rapid growth of agricultural production.

ចាប់ពីឆ្នាំ១៩៨៩ ប្រព័ន្ធធនាគារត្រូវបានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ ។ ធនាគារខេត្ត-ក្រុងត្រូវបានប្តូរឈ្មោះទៅជាធនាគារឯកទេសខេត្ត-ក្រុង ដែលធ្វើសកម្មភាពតាមរបបស្វ័យភិបាលសេដ្ឋកិច្ច និងស្វ័យភាពហិរញ្ញវត្ថុ និងធ្វើសកម្មភាពនៅលើតំបន់ដែនដីរបស់ខ្លួន ។ ធនាគារជាតិនៃប្រជាជនកម្ពុជាបានបំពេញតួនាទីបញ្ជាណែនាំ និងត្រួតពិនិត្យធនាគារឯកទេសទាំងនោះ ។ មុខងារជាបេឡាថវិការដ្ឋក៏ត្រូវបានផ្ទេរទៅឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញតាំងពីចុងឆ្នាំ១៩៩១ ។

សរុបសេចក្តីមក ដំណាក់កាលឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ អាចត្រូវបានចាត់ទុកថាជាការកកើតឡើងប្រកបដោយវីរភាពនិងការលះបង់ខ្ពស់ ដែលបានជួយគាំទ្រដល់រដ្ឋកម្ពុជាឱ្យមានស្ថានភាពរឹងមាំ ដើម្បីដំណើរការចរចាសន្តិភាព បង្រួបបង្រួមជាតិ និងការកសាងព្រះរាជាណាចក្រកម្ពុជាទី២ឡើងវិញ ។

From 1989, the banking system was reformed gradually. The provincial and municipal banks were simultaneously transformed into specialized provincial and municipal banks, economically and financially autonomous and operating only in the territory of the province where they were located. The PNBK played its authorities role that could direct and supervise those specialized banks. Late in 1991, the function of the state budgetary cashier was transferred back to the Ministry of Economy and Finance. Foreign investment in banking activity started mid-1991.

In summary, the period from 1979-1993 can be seen as the establishment of the banking system, with patrio- tism and high sacrifice. These factors helped strengthen the State of Cambodia, therefore enabling it to conduct negotiations for national unification and the re-establishment of the second Kingdom of Cambodia.

## ២. ដំណាក់កាលក្រោយឆ្នាំ១៩៩៣រហូតដល់បច្ចុប្បន្ន

លទ្ធផលនៃការបោះឆ្នោតទូទាំងប្រទេសលើកទី១នាឆ្នាំ១៩៩៣ បាននាំមកនូវបរិយាកាសថ្មីដល់ប្រជាជាតិទាំងមូលក៏ដូចប្រព័ន្ធធនាគារដែរ ។ នោះគឺការបើកទ្វារចំហទៅកាន់ពិភពលោក ការឧបត្ថម្ភគាំទ្រយ៉ាងទូលំទូលាយពីសហគមន៍អន្តរជាតិ ការអនុវត្តន៍របបសេដ្ឋកិច្ចទីផ្សារ ការវិលមកកសាងសង្គមជាតិវិញនៃប្រជាជនកម្ពុជាគ្រប់ទិសទី និងគ្រប់និន្នាការនយោបាយ ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ការកសាងនីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ។




ក្រដាសប្រាក់រៀលនិងកាស បោះពុម្ពដោយធនាគារជាតិនៃកម្ពុជា
ក្នុងអំឡុង ឆ្នាំ១៩៩៥-បច្ចុប្បន្ន

ប្រព័ន្ធធនាគារកម្ពុជាផ្តើមមានការប្រែប្រួលជាថ្មីចាប់ពីឆ្នាំ១៩៩២ ពោលគឺ បើកទូលាយអាជីវកម្មលើវិស័យ ធនាគារដោយបង្កើតឡើងនូវ ធនាគារពាណិជ្ជទាំងឡាយក្រោមច្បាប់ក្នុងស្រុក ឬក្រោមទម្រង់ជាសាខាធនាគារបរទេស ។ ប្រការនេះតំរូវឱ្យធនាគារជាតិនៃកម្ពុជា ត្រូវពង្រឹងតួនាទីជាធនាគារកណ្តាល បង្កើនសមត្ថភាពបញ្ជា ណែនាំនិងត្រួតពិនិត្យបណ្តាធនាគារពាណិជ្ជ ដែលពេលនោះមានចំនួន ៣២ ធនាគារពាណិជ្ជ ។

The result of the nationwide general election in 1993 brought a new environment to the entire nation as well as to the banking system. It included opening the door to the world, wide support from the international community, the adoption of a market economy, the return of Cambodian people from all political tendencies and places to the reconstruction of the nation, the practice of democracy, the building of a legal state and respecting human rights.

The Cambodian banking system has undergone new changes since 1992 with opening-up of banking operations through the establishment of commercial banks under local laws or as foreign branches. This required the National Bank of Cambodia to strengthen its role as a Central Bank and improve its management capacity in order to supervise the 32 commercial banks that were established at that time.

ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅឆ្នាំ១៩៩៦ បានកំណត់ឱ្យធនាគារជាតិនៃកម្ពុជាមានបេសកកម្មចំបងគឺ កំណត់និងដឹកនាំនយោបាយរូបិយវត្ថុដើម្បីរក្សាថ្លៃឱ្យមានស្ថិរភាព ។ លក្ខណៈជាប្រព័ន្ធធនាគារពីរថ្នាក់តាមបែបផែនសេដ្ឋកិច្ចទីផ្សារសេរីដែលនៅថ្នាក់ទី១មានធនាគារជាតិនៃកម្ពុជា និងនៅថ្នាក់ទី២មានធនាគារពាណិជ្ជ ក៏បានរៀបចំនិងពង្រឹងជាបន្តបន្ទាប់ទាំងរចនាសម្ព័ន្ធនិងយន្តការការងារ ។ ទន្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាបានធ្វើឱ្យសំរេចជាមូលដ្ឋានក្នុងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថេរភាពតំលៃប្រាក់រៀល ស្ថេរភាពអត្រាប្តូរប្រាក់ និងការបង្កើនទុនបំរុងអន្តរជាតិ ។

ចាប់តាំងពីឆ្នាំ១៩៩៣ ក្នុងដំណើរអនុវត្តសេដ្ឋកិច្ចទីផ្សារ ធនាគារជាតិនៃកម្ពុជាមិនទាន់មាននៅឡើយនូវឧបករណ៍រូបិយវត្ថុដ៏មានប្រសិទ្ធិភាព សំរាប់កំណត់និងដឹកនាំនយោបាយរូបិយវត្ថុ ដើម្បីរួមចំណែករក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចដែលជាមូលដ្ឋានសំរាប់រក្សាស្ថេរភាពថ្លៃ ។ ជាអាទិ៍អត្រាការប្រាក់គ្មានឥទ្ធិពលទៅលើការចលនាសញ្ច័យ ប្រតិបត្តិការទីផ្សារចំហមិនទាន់អាចធ្វើបានដោយគ្មានប័ណ្ណរតនាគារ ។ល។ កត្តាទាំងនេះបានរារាំងដល់ការបញ្ជូចរាចររូបិយវត្ថុ ។

ប្រព័ន្ធធនាគារកម្ពុជានៅខ្សោយ ទាំងខាងដែនប្រតិបត្តិការ និងវិសាលភាពដែនដី ។ នៅថ្នាក់ទី១ ទីស្នាក់ការកណ្តាលនៃធនាគារជាតិនៃកម្ពុជាទើបនឹងបានរៀបចំរចនាសម្ព័ន្ធ និងចាត់តាំងក្បាលម៉ាស៊ីនបានពេញលេញក្នុងឆ្នាំ ១៩៩៨ ។ សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងកំពុងស្ថិតក្នុងសភាពស្រពិចស្រពិលតាំងពីឆ្នាំ១៩៩៣មក ដែលនាំឱ្យថមថយខាងប្រតិបត្តិការ និងធ្លាក់ទន់ខ្សោយខាងការដឹកនាំគ្រប់គ្រង ។ នៅថ្នាក់ទី២ ធនាគារ ពាណិជ្ជទាំងឡាយបានបង្កើតឡើងក្នុងដំណាក់កាលដែលសេដ្ឋកិច្ចជាតិកំពុងត្រូវបានរៀបចំសណ្តាប់ធ្នាប់តាមបែបផែនសេដ្ឋកិច្ចទីផ្សារ ហើយស្ថេរភាពនយោបាយ សេដ្ឋកិច្ច និងសង្គម នៅពេលនោះនៅផុយស្រួយនៅឡើយ ។ ម្ល៉ោះហើយសកម្មភាពប្រតិបត្តិការធនាគារក៏មិនទាន់បានពង្រីកឱ្យទូលាយនៅឡើយដែរ ។ សកម្មភាពមីក្រូហិរញ្ញវត្ថុបានកើតឡើងដោយឯកឯងទៅតាមសំណូមពររបស់ប្រជាជននៅតាមតំបន់នានា ហើយទាមទារត្រូវតែរៀបចំគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់ ។

The Law on the Organization and Conduct of the National Bank of Cambodia, adopted in 1996 by the National Assembly, specifies that the principal mission of the National Bank of Cambodia is to determine and direct the monetary policy, aimed at maintaining price stability. Both structures and working mechanisms of the 2-tier banking system of a free market economy, of which tier 1 is the National Bank of

Cambodia and tier 2 are commercial banks, were gradually organized and strengthened. At the same time, the National Bank of Cambodia basically maintained the macroeconomic stability, the internal value of the Riel, the stability of the exchange rate, and meanwhile increasing international reserves.

Yet, since 1993, in the process of adopting to a market economy the NBC has not had effective monetary instruments to determine and direct monetary policy, aimed at maintaining the macro-economy as a basis for price stability. Likewise, interest rates have had no impact on savings mobilization. Open market operations cannot be run since Treasury bills are not available etc. Consequently, these factors have refrained the National Bank of Cambodia from successfully directing currency circulation.

The Cambodia banking system is still weak in both operational aspects and territorial coverage. In tier1, the head office of the National Bank of Cambodia has just been structured and the leadership hierarchy was fully assigned in 1998. Since 1993, the branches of National Bank of Cambodia have lacked direction, as result of weak operations and poor management. In tier 2, commercial banks were established when the national economy was in the process of transforming from a command into a free market economy. The political, economic and social stability at that time was still fragile, so banking operational activities could not be expanded either. The activities of micro-finance have naturally been established in accordance with the needs of people in various rural areas and those micro-finance institutions need to be firmly supervised.

ទន្ទឹមនឹងនេះ ជំនឿលើប្រាក់រៀលនិងលើប្រព័ន្ធធនាគារនៅខ្សោយនៅឡើយ ដោយសារលក្ខណៈប្រវត្តិសាស្ត្រ គឺការលុបបំបាត់ចោលរូបិយវត្ថុនិងប្រព័ន្ធធនាគារនៅក្នុងរបបប៉ុលពត និងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាងពីរទសវត្សកន្លងមក ។ អស្ថេរភាពតំលៃប្រាក់រៀល អស្ថេរភាពនយោបាយ សេដ្ឋកិច្ច សង្គម ព្រមទាំងសមត្ថភាព និងគុណភាពនៃប្រតិបត្តិការរបស់ប្រព័ន្ធធនាគារដែលនៅមានកំរិត ក៏ជាមូលហេតុមួយទៀត ធ្វើឱ្យថមថយនូវជំនឿទុកចិត្តលើប្រាក់រៀល និងលើប្រព័ន្ធធនាគារ ។

ប៉ុន្តែធនាគារជាតិនៃកម្ពុជាមានចំណុចប្រសើរខាងផ្លូវច្បាប់ ដោយបានរដ្ឋសភាអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ និងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានទទួលការគាំទ្រយ៉ាងកក់ក្តៅពីរាជរដ្ឋាភិបាល ពីធនាគារកណ្តាលនៃបណ្តាប្រទេស ព្រមទាំងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ជាពិសេសមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ទន្ទឹមនេះ មូលនិធិរូបិយវត្ថុអន្តរជាតិក៏បានធ្វើការចរចានិងអនុម័តឡើងវិញនូវកម្មវិធីឥណទាន គាំទ្រដល់ការពង្រឹងការកែទំរង់រចនាសម្ព័ន្ធ (ESAF) ដែលបច្ចុប្បន្ននេះហៅថា កម្មវិធីកាត់បន្ថយ

ភាពក្រីក្រ និងបង្កើនកំណើនសេដ្ឋកិច្ច (PRGF) ។

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ យុទ្ធនាការផ្តល់អាជ្ញាប័ណ្ណឡើងវិញដល់ធនាគារដែលកំពុងធ្វើប្រតិបត្តិការត្រូវបានធ្វើឡើងដើម្បីពង្រឹងប្រព័ន្ធធនាគារ តាមរយៈជំរុញឱ្យបណ្តាធនាគារទាំងនោះដាក់ពាក្យសុំអាជ្ញាប័ណ្ណជាថ្មីឡើងវិញ និងអនុវត្តតាមបទបញ្ញាប្រុងប្រយ័ត្នថ្មីរបស់ធនាគារជាតិនៃកម្ពុជា ។ ជាលទ្ធផល ធនាគារដែលមិនអាចបន្តសកម្មភាពបានត្រូវបានបិទទ្វារ ហើយធ្វើការជំរះបញ្ជី ។

Similarly, due to the past policy of eliminating currency and banking system under the Pol Pot regime and experiencing more than two decades of civil war, the Cambodia people are not very confident in their own currency or the banking system. The Riel's value has been affected by social, political and economic instability as well as the limited capacity and quality of the banking system has weakened confidence in the Riel.

However, the National Bank of Cambodia scored several points regarding the legal framework as the National Assembly, so far, has adopted the Law on the Organization and Conduct of the National Bank of Cambodia, the Law on Foreign Exchange, and the Law on Banking and Financing Institutions. Furthermore, the National Bank of Cambodia the Royal government, the central banks of other countries and international financial institutions, especially the International Monetary Fund. At the same time, the International Monetary Fund has resumed the negotiation of the credit program supporting the strengthening of structural reform, presently focusing on poverty reduction and economic growth.

According to the Law on Banking and Financial Institutions promulgated by the National Assembly on November 18, 1999 all existing banks in Cambodia had been restructured in order to strengthen the banking system. They had to reapply for new licenses and have to be complied with the NBC's new regulations. As a result, non-viable banks were closed and liquidated.

# ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

អនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ត្រង់ជំពូកទី៤ ស្តីពីការគ្រប់គ្រងធនាគារកណ្តាល មាត្រា១២ ត្រង់ចំណុច១ បានចែងថា ÷ អង្គការគ្រប់គ្រងរបស់ធនាគារកណ្តាលគឺក្រុមប្រឹក្សាភិបាល ដែលតទៅនេះហៅកាត់ថាក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាត្រូវបានដឹកនាំដោយទេសាភិបាល ។

ក្រុមប្រឹក្សាមានសមាជិក៧រូប ដែលបច្ចុប្បន្នមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| -ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| -ឯកឧត្តម អេង ថ្លាយសាន | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| -ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | តំណាងអោយប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| -ឯកឧត្តម អ៊ីវ ថុង | តំណាងអោយមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| -លោក ជូ គីមឡេង | តំណាងអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| -លោក ឡាយម៉េងស៊ុន | តំណាងអោយមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| -លោកស្រី ម៉ៅ សុន | តំណាងអោយបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក |



សកម្មភាពប្រជុំការងាររបស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា

# ការអនុវត្តន៍បេសកកម្មរបស់ធនាគារជាតិនៃកម្ពុជា

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសអោយប្រើក្នុងឆ្នាំ ១៩៩៦ បានកំណត់បេសកកម្មចំបងរបស់ធនាគារជាតិនៃកម្ពុជាគឺ រក្សាស្ថេរភាពថ្លៃ ។ ក្នុងការអនុវត្តន៍បេសកកម្មនេះធនាគារជាតិនៃកម្ពុជាត្រូវបំពេញតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម :

**បោះផ្សាយរូបិយវត្ថុ :**

ភារកិច្ចដំបូងបំផុតគឺបោះផ្សាយរូបិយវត្ថុជាតិ (ប្រាក់រៀល) ក្នុងន័យនេះ បទប្បញ្ញត្តិជាធរមានបានតំរូវឱ្យប្រជាជនកម្ពុជាទទួលយកប្រាក់រៀលជាការទូទាត់បំណុលទាំងឡាយ ។ ក្នុងស្ថានភាពជាក់ស្តែងប្រាក់ដុល្លារអាមេរិកបានធ្វើចរាចរយ៉ាងទូលំទូលាយ ប៉ុន្តែពុំមានន័យថាប្រាក់រៀលត្រូវបានបដិសេធក្នុងការទូទាត់នៃការទិញទំនិញទេ ផ្ទុយទៅវិញ ច្បាប់បានកំណត់ការពិន័យរហូតដល់១០០ដងពីលើទឹកប្រាក់នៃប្រតិបត្តិការបើជនណាប្រកែកពុំព្រមទទួលយកការទូទាត់ជាប្រាក់រៀល ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ធនាគារជាតិនៃកម្ពុជាមានបំពាក់ដោយរោងពុម្ពពិសេស មានលទ្ធភាពអាចបោះពុម្ពប្រភេទធនប័ត្រមួយចំនួនធំ ។

**កំណត់និងដឹកនាំនយោបាយរូបិយវត្ថុ :**

ក្នុងការទទួលខុសត្រូវកំណត់និងដឹកនាំនយោបាយរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាអាចផ្តល់ហិរញ្ញ-ប្បទានដល់ធនាគារ និងធ្វើអន្តរាគមន៍លើទីផ្សាររូបិយវត្ថុ ដើម្បីជះឥទ្ធិពលដល់អត្រាការប្រាក់ ។ ធនាគារជាតិនៃកម្ពុជាអាចចេញផ្សាយបទបញ្ជាលើស្ថាប័នឥណទាន ដើម្បីកំណត់ទុនបំរុងនិងជះឥទ្ធិពលលើសាច់ប្រាក់ងាយស្រួល ។

បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាមិនទាន់អាចអនុវត្តភារកិច្ចនេះបានខ្លាំងក្លា ដោយសារមូលហេតុពីរយ៉ាង :

**ទីមួយ** គឺបណ្តាលមកពីដុល្លារូបនីយកម្មនៃសេដ្ឋកិច្ច : ភាគច្រើនលើសលុបនៃប្រាក់បញ្ញើនិងឥណទាន សុទ្ធតែចារិកជាប្រាក់ដុល្លារអាមេរិក ហិរញ្ញប្បទានទៅដល់ធនាគារអាជីវកម្មមិនអាចហួសពីកំរិតទុនបំរុងអន្តរជាតិដែលកាន់កាប់ដោយធនាគារកណ្តាលទេ ។ អត្រាការប្រាក់ដែលអនុវត្តលើទីផ្សារក្នុងស្រុកគឺជាអត្រាដែលប្រើប្រាស់ដោយទីផ្សារដុល្លារអន្តរជាតិ ដូច្នេះកត្តាជះឥទ្ធិពលក្នុងស្រុកអាចគ្រាន់តែមានប្រសិទ្ធភាពមធ្យមល្មមតែប៉ុណ្ណោះ ។

**ទីពីរ** គឺជាមូលហេតុនៃការសល់ទំនេរសាច់ប្រាក់ ដែលប្រព័ន្ធធនាគារនៅកម្ពុជាកំពុងជួបប្រទះបច្ចុប្បន្ននេះ។ ក្នុងការបំពេញកាតព្វកិច្ចតាមច្បាប់កំណត់ ធនាគារពាណិជ្ជទាំងឡាយត្រូវបំពេញដើមទុនលើសជាងពីរដង (ពី១០ពាន់លានរៀលទៅ៥០ពាន់លានរៀល) ដែលជាមួយគ្នានោះ ការអភិវឌ្ឍន៍តំរូវការផ្នែកឥណទានពុំបានស្របគ្នាទេ ហើយហេតុនេះបានធ្វើឱ្យមានការគរសល់ទំនេរសាច់ប្រាក់ក្នុងប្រព័ន្ធធនាគារទាំង

មូល ដូច្នេះ ធនាគារអាជីវកម្មក្លាយជាអ្នកសល់ប្រាក់ឱ្យខ្ចី (Net Lender) ធៀបជាមួយធនាគារជាតិនៃកម្ពុជា ។ ក្នុងករណីនេះ នយោបាយរូបិយវត្ថុគ្រាន់តែអាចមានប្រសិទ្ធភាពក្នុងនិន្នាការកើនឡើងនៃអត្រាការប្រាក់ ពោលគឺ យុទ្ធសាស្ត្រស្រូបយកសាច់ប្រាក់ទាំងមូល ។ ប្រការនេះ ធនាគារជាតិនៃកម្ពុជាបានចាត់ទុកថាជាស្ថានភាពល្អប្រសើរដែលត្រូវប្រកាន់យក ព្រោះថា ក្នុងបរិដ្ឋានមួយដែលធនាគារពាណិជ្ជខ្លះមានការដួលរលំប្រព័ន្ធ ធនាគារមានសាច់ប្រាក់ងាយស្រួលសល់កាន់តែច្រើនកាន់តែល្អ ។

## ជាទីប្រឹក្សាអមរាជរដ្ឋាភិបាល

ធនាគារជាតិនៃកម្ពុជាមានភារកិច្ចសិក្សាស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុ និងដាក់ជូនរាជរដ្ឋាភិបាលនូវសំណើនៃវិធានផ្សេងៗក្នុងវិស័យនេះ ពោលគឺជាអ្នកស្រាយបំភ្លឺជូនរាជរដ្ឋាភិបាលនៅលើរាល់បញ្ហាទាំងអស់ដែលអាចជះឥទ្ធិពលដល់ការសំរេចគោលដៅនយោបាយរបស់រាជរដ្ឋាភិបាល ។ ក្នុងរយៈពេលយ៉ាងតិច ៦ខែម្តង ធនាគារជាតិនៃកម្ពុជាត្រូវរាយការណ៍ស្តីពីការវាយតំលៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេស កសាងតុល្យការនៃនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ ដែលបានអនុវត្តន៍កន្លងមក និងលើកឡើងពីទិសដៅដែលត្រូវបំពេញក្នុងឆមាសខាងមុខទៀត ។

## ត្រួតពិនិត្យស្ថានភាពធនាគារនិងហិរញ្ញវត្ថុ

ជាអ្នកផ្តល់អាជ្ញាប័ណ្ណអនុញ្ញាតឱ្យធ្វើអាជីវកម្ម ចេញបទបញ្ញត្តិផ្សេងៗ និងជាអ្នកត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជាមានការទទួលខុសត្រូវនេះកាន់តែធ្ងន់ធ្ងរនៅក្នុងលក្ខខណ្ឌដែលអំណាចបានធ្លាក់មកក្នុងដៃ ប៉ុន្តែ មធ្យោបាយនិងឧបករណ៍នៅមានកំរិតខ្វះខាតនៅឡើយ ។ ធនាគារជាតិនៃកម្ពុជាកំពុងខិតខំពង្រឹងប្រព័ន្ធត្រួតពិនិត្យមួយដែលមានស្តង់ដារស្របតាមប្រទេសជឿនលឿន ។

## គ្រប់គ្រងទុនបំរុង

ធនាគារជាតិនៃកម្ពុជាទទួលភារៈកិច្ចរក្សា និងគ្រប់គ្រងទុនបំរុងអន្តរជាតិរបស់ប្រទេស ក្នុងគោលដៅរក្សានូវបរិមាណមួយគ្រប់គ្រាន់សំរាប់ធានាឱ្យប្រតិបត្តិការអន្តរជាតិរបស់ប្រទេស ។ ធាតុរួមផ្សំចំបងនៃទុនបំរុងនេះរួមមានមាស និងប្រាក់ដុល្លារអាមេរិក ។ ប្រាក់ដុល្លារអាមេរិកជាឯកតាដែលត្រូវបានចារឹកប្រើនៅស្ទើរតែលើប្រតិបត្តិការពាណិជ្ជកម្មក្រៅប្រទេសទាំងអស់របស់កម្ពុជា ។ ដោយហេតុថាទំហំប្រាក់បញ្ញើជាដុល្លារមានសមាមាត្រធំ (មានតែ៥%នៃប្រាក់បញ្ញើធនាគារបានចារឹកជាប្រាក់រៀល) គេអាចនិយាយថាទុនបំរុង គឺច្រើនតែបំរើឱ្យគោលដៅទុនបំរុងសាច់ប្រាក់ងាយស្រួល ។

ធនាគារជាតិនៃកម្ពុជាមានការប្រុងប្រយ័ត្នក្នុងការរក្សាកំពស់ទុនបំរុងឱ្យស្ថិតក្នុងកំរិតខ្ពស់ជាងទំហំនៃការនាំចូលចំនួន៣ខែជានិច្ច ។

## ត្រួតពិនិត្យប្រព័ន្ធទូទាត់

សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្នកំពុងដំណើរការជាសារវន្តដោយឆ្លងការទូទាត់ដោយប្រើសាច់ប្រាក់រៀល ឬរូបិយប័ណ្ណ ។ ក្រដាសប្រាក់រៀលដណ្តើមសមាមាត្រមួយភាគបួននៃបរិមាណរូបិយវត្ថុក្នុងចរាចរណ៍ ។ តាមការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បើបូកបន្ថែមក្រដាសប្រាក់ដុល្លារទៀតយើងបានសមាមាត្រនេះកើនស្មើប្រហែល៩០% ។ ដូច្នេះ សកម្មភាពរបស់ធនាគារជាតិនៃកម្ពុជាក៏បានយកចិត្តទុកដាក់លើការបង្កើតឱ្យមានឧបករណ៍ទាំងឡាយដែលជួយឱ្យការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ដ៏ទំនើប ដូចជាការបង្កើតសភាផាត់ទាត់មូលប្បទានប័ត្រ (ជាប្រាក់រៀលពីឆ្នាំ១៩៩៤ និងបន្ថែមជាប្រាក់ដុល្លារពី ឆ្នាំ២០០១) ហើយក្នុងពេលថ្មីៗនេះទៀត សេចក្តីព្រាងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់ការសងប្រាក់ ក៏ត្រូវបានបញ្ចប់និងដាក់ជូនរដ្ឋសភាពិនិត្យអនុម័ត ។

ធនាគារជាតិនៃកម្ពុជាកំពុងជួបការលំបាកក្នុងការគ្រប់គ្រងលំហូរនៃមូលនិធិ ដោយហេតុថាមានបណ្តាញក្រៅផ្លូវការនៃការផ្ទេរប្រាក់ចូលនិងចេញទៅក្រៅប្រទេស ។ តាមការបញ្ញត្តិក្នុងច្បាប់ រាល់ប្រតិបត្តិការដែលចាត់ថាជាសកម្មភាពធនាគារ គ្រាន់តែអាចប្រកាន់យកជាប្រក្រតីដោយស្ថាប័នដែលបានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាប៉ុណ្ណោះ ។ ខ្លឹមសារនេះ មានការលំបាកសំរាប់ឱ្យប្រតិបត្តិករក្រៅផ្លូវការទាំងនោះទទួលយកណាស់ ព្រោះថា ដើម្បីក្លាយជាស្ថាប័នទទួលការអនុញ្ញាត(ធនាគារ) គេត្រូវគោរពឱ្យបានលក្ខខណ្ឌជាច្រើនដែលក្នុងនោះមានការបំពាក់នូវដើមទុន និងប្រព័ន្ធពត៌មាន ។ល។ ដូច្នេះហើយធនាគារជាតិនៃកម្ពុជាបានសំណូមពរឱ្យប្រតិបត្តិករផ្ទេរប្រាក់ទាំងឡាយចូលជ្រកក្រោមនាមករណ៍ធនាគារ ដើម្បីទទួលការគ្របដណ្តប់អំពីវិស័យកិរិតមូលនិធិសម្បត្តិសុទ្ធ និងការត្រួតពិនិត្យផ្ទៃក្នុងជាដើម ។

## សេវាកម្មធនាគារសំរាប់រដ្ឋ

មិនមែនគ្រាន់តែជាទីប្រឹក្សារាជរដ្ឋាភិបាលប៉ុណ្ណោះទេ តែធនាគារជាតិនៃកម្ពុជាក៏ជាធនាគារិករបស់រដ្ឋផងដែរ ។ ធនាគារជាតិនៃកម្ពុជាបើកគណនីជូនរាជរដ្ឋាភិបាល និងបំរើការទូទាត់លើគណនីទាំងនោះ ។ បើពិនិត្យអំពីសេវាកម្មធនាគារនៅក្នុងស្រុកឃើញថា នៅមានការរាំងដែលបណ្តាលមកពីមូលហេតុបីយ៉ាង :

**ទីមួយ** : ការញែកឱ្យដាច់ស្រឡះរវាងមុខងារធនាគារជាតិនៃកម្ពុជា ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅពុំទាន់បានម៉ឺងម៉ាត់គ្រប់ទីកន្លែងនៅឡើយ ។ នៅតាមខេត្តក្រុងជាច្រើន សេវាកម្មរបស់រតនាគារជាតិបានបំរើឱ្យការទទួលចំណូលដោយផ្ទាល់ ហើយធ្វើការទូទាត់ចំណាយក៏ដោយផ្ទាល់ ផ្តើមចេញពីចំណូលជាសាច់ប្រាក់ទាំងនោះ គឺពុំមានឆ្លងកាត់បេឡា និងគណនីនៅធនាគារជាតិនៃកម្ពុជាទេ ។ លទ្ធផលនៃទង្វើនេះបាននាំឱ្យមានការខ្វះខាតអំពីការជ្រើសរើសនិងបង្វិលគុណភាពក្រដាសប្រាក់ ហើយក្រដាសប្រាក់ដែលមិនមានគុណភាពគ្រប់គ្រាន់បានវិលចូលនិងនៅតែបន្តធ្វើចរាចរដដែល ។

**ទីពីរ** : ភាពទន់ខ្សោយនៃបណ្តាញធនាគារពុំអាចបំរើឱ្យការផ្គត់ផ្គង់របស់រដ្ឋបានគ្រប់គ្រាន់ទេ ។ អវត្តមាននៃសកម្មភាពរបស់ភ្នាក់ងារធនាគារនៅតាមចំណុចដៅដែលមានចំណូល ចំណាយសំខាន់ៗ រដ្ឋចាំបាច់ត្រូវប្រើមធ្យោបាយផ្ទាល់របស់ខ្លួនក្នុងការដឹកជញ្ជូនសាច់ប្រាក់ ។

**ទីបី** : កំរិតធនាគារូបនីយកម្មទាប ពោលគឺទំហំនៃការទូទាត់ដោយមិនប្រើសាច់ប្រាក់មានកំរិតទាប ។ សេវាកម្មក្នុងស្រុកដែលធនាគារជាតិនៃកម្ពុជាកំពុងបំរើជូនរដ្ឋ ស្ទើរតែជាសេវាកម្មបេឡាទាំងស្រុង ហើយមានតែការទូទាត់ក្នុងវិស័យអន្តរជាតិទេ ដែលភាគច្រើនជាការទូទាត់ដោយបង្វែរគណនី ។ សកម្មភាពសេវាកម្មរបស់ធនាគារជាតិនៃកម្ពុជានេះត្រូវតែយកចិត្តទុកដាក់អភិវឌ្ឍន៍ក្នុងអនាគត ។

**សេវាកម្មសំរាប់ធនាគារអាជីវកម្ម :**

ដោយមូលហេតុប្រវត្តិសាស្ត្រ ធនាគារជាតិនៃកម្ពុជាធ្វើប្រតិបត្តិការទូទាត់អន្តរជាតិមួយចំនួនធំសំរាប់បំរើឱ្យធនាគារពាណិជ្ជ ។ កាលពីក្រោមរបបសេដ្ឋកិច្ចផែនការ ធនាគារជាតិនៃកម្ពុជាធ្លាប់បានដើរតួនាទីជាធនាគារពាណិជ្ជ តាមរយៈនាយកដ្ឋានមួយរបស់ខ្លួន ដើម្បីអនុវត្តការផ្ទេរប្រាក់អន្តរជាតិបំរើឱ្យធនាគារពាណិជ្ជដទៃទៀត និងសហគ្រាស ។ ទំលាប់នេះនៅដក់សល់នៅឡើយ អាស្រ័យដោយធនាគារទំនាក់ទំនងជាដៃគូនៅបរទេស នៅតែចង់បានធនាគារកណ្តាលមួយជាអតិថិជនសំរាប់បំរើសេវាកម្មទូទាត់រវាងគ្នា ។ រហូតមកដល់បច្ចុប្បន្ន សកម្មភាពនេះបានថយចុះព្រោះនាយកដ្ឋាននោះ (ធនាគារពាណិជ្ជកម្មក្រៅប្រទេស) បានត្រូវផ្តាច់ចេញជាធនាគាររដ្ឋ ធ្វើអាជីវកម្មក្នុងនាមជាធនាគារពាណិជ្ជសុទ្ធសាធ និងត្រូវស្ថិតនៅក្នុងដំណើរការឯកជនភាវូបនីយកម្មផង ។

ប្រភេទសេវាកម្មរបស់ធនាគារជាតិនៃកម្ពុជាមួយទៀតដែលបានអភិវឌ្ឍយ៉ាងឆាប់រហ័សនោះគឺសេវាកម្មជាបេឡានៃក្រដាស់ប្រាក់បរទេស ។

ប្រព័ន្ធធនាគារកម្ពុជា "ជាអ្នកនាំចេញសុទ្ធ" នូវក្រដាសប្រាក់ដុល្លារយ៉ាងទៀងទាត់ ដោយហេតុថាការចំណាយទាំងឡាយរបស់អ្នកទេសចរបរទេសនៅកម្ពុជា បានគរពូនក្រដាសប្រាក់ដុល្លារលើសពីតំរូវការប្រើរបស់សេដ្ឋកិច្ចកម្ពុជា ។ ក្រដាសប្រាក់ដុល្លារបានហូរចូលប្រព័ន្ធធនាគារដែលចាំបាច់ត្រូវតែធ្វើការលក់ដូរទៅក្រៅប្រទេសសំរាប់បញ្ចូលទៅក្នុងគណនី ។ ធនាគារជាតិនៃកម្ពុជាកំពុងដើរតួជាអ្នករកស៊ីដុំនៃក្រដាសប្រាក់ដុល្លារ ដោយទទួលការបង់ចូលឬដកចេញពីសំណាក់ធនាគារ ធ្វើការពិនិត្យជ្រើសរើស និងនាំចេញទៅបរទេសដោយពុំបានទទួលនូវកំរៃអ្វីឡើយ ។ សកម្មភាពនេះមាននិន្នាការកើនឡើង ហើយសុវត្ថិភាពនៃការដឹកជញ្ជូនកំពុងចោទជាបញ្ហាសំរាប់ធនាគារជាតិនៃកម្ពុជាដែលត្រូវពិចារណា ។

# ប្រព័ន្ធធនាគារនៅកម្ពុជា និងដុល្លារូបនីយកម្ម

## ទស្សនៈអំពីប្រព័ន្ធធនាគារនៅកម្ពុជា

ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាមានប្រវត្តិខ្លីបង្គួរ ដែលត្រូវបានបង្កើតឡើងជាមួយនឹងការបង្កើតឡើងវិញនៃធនាគារកណ្តាលនៅឆ្នាំ ១៩៨០ ។

បច្ចុប្បន្ន ប្រព័ន្ធហិរញ្ញវត្ថុមានការអភិវឌ្ឍន៍តិចតួចបំផុត ហើយរួមមានតែស្ថាប័នធនាគារស្ទើរទាំងអស់ ។ ប្រព័ន្ធធនាគារបច្ចុប្បន្នបានត្រូវបង្កើតឡើងជា៤ប្រភេទផ្អែកទៅតាមមុខងារ÷

- ធនាគារកណ្តាលដែលជាធនាគារជាតិនៃកម្ពុជា មានសាខាខេត្តក្រុងរបស់ខ្លួនចំនួន២០
- ធនាគារពាណិជ្ជចំនួន១៤ដែលក្នុងនោះ ធនាគារចំនួន៩ត្រូវបានបង្កើតឡើងដោយច្បាប់ក្នុងស្រុក ៤ជាសាខាធនាគារបរទេស និង១ជាធនាគាររដ្ឋ ( ធនាគារពាណិជ្ជកម្មក្រៅប្រទេស)
- ធនាគារឯកទេសចំនួន៤ ដែលរួមមានធនាគាររដ្ឋ គឺធនាគារអភិវឌ្ឍន៍ជនបទ ហើយនិង៣ជាធនាគារដែលគ្រប់គ្រងដោយឯកជន និង
- ប្រព័ន្ធធនាគារវិមជ្ឈការ រួមមានអង្គការក្រៅរដ្ឋាភិបាល (NGOs) មួយចំនួនដែលកំពុងធ្វើប្រតិបត្តិការហិរញ្ញវត្ថុជនបទ ។

## ទិសដៅគោលនយោបាយរូបិយវត្ថុ

ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ធនាគារកណ្តាលមានបេសកកម្មចំបងគឺ កំណត់និងដឹកនាំនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាថ្លៃឱ្យមានស្ថេរភាព សំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចំរើន ។

នៅក្នុងបរិបទនេះ ស្ថេរភាពថ្លៃអាចត្រូវបានគេយល់ដឹងតាមវិធី២យ៉ាង ÷

- ស្ថេរភាពថ្លៃតាមន័យចង្អៀតមានន័យថា រក្សាអតិផរណាឱ្យនៅទាប និងមិនប្រែប្រួល ហើយ
- ស្ថេរភាពថ្លៃក្នុងន័យទូលាយមានន័យថា ធ្វើឱ្យតម្លៃរូបិយវត្ថុមានស្ថេរភាព ។ តម្លៃរូបិយវត្ថុជាតិមានស្ថេរភាពគឺជាលក្ខខណ្ឌដំបូងសំរាប់ស្ថេរភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងកំណើនសេដ្ឋកិច្ច ។ ប្រសិនបើលក្ខខណ្ឌនេះមិនបានសំរេច យើងមិនអាចបន្តប្រើរូបិយវត្ថុជារៀងរាល់ថ្ងៃប្រកបដោយទំនុកទុកចិត្តទាំងស្រុងនៅក្នុងតម្លៃរបស់វាទេ ។

ប្រព័ន្ធអត្រាប្តូរប្រាក់សមស្រប ដែលគាំទ្រដោយគោលនយោបាយសេដ្ឋកិច្ចជាសារវន្តផ្សេងទៀត និងគោលនយោបាយរចនាសម្ព័ន្ធគឺជាមូលដ្ឋានសំខាន់បំផុតសំរាប់ធ្វើឱ្យសំរេចនូវទិសដៅដែលបានពោលខាងលើ ។

## របបអត្រាប្តូរប្រាក់_ការអភិវឌ្ឍន៍ជាប្រវត្តិសាស្ត្រ

អស់រយៈពេលប្រហែល៤ឆ្នាំ ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់នៅក្រោមការក្តាប់គ្រងរបស់របបប្រល័យពូជសាសន៍ប៉ុលពត ជារបបមួយដែលបានបំផ្លាញខ្ទេចខ្ទីនូវហេដ្ឋារចនាសម្ព័ន្ធនៃសេដ្ឋកិច្ចដែលទន់ខ្សោយស្រាប់ ។ នៅក្រោមរបបនេះ គ្មានផ្សារ គ្មានពាណិជ្ជកម្ម ហើយប្រព័ន្ធរូបិយវត្ថុ និងធនាគារត្រូវបានលុបបំបាត់ មិនតែប៉ុណ្ណោះអគារធនាគារជាតិនៃកម្ពុជាត្រូវបានកំទេចចោលទាំងស្រុង ដូច្នេះប្រព័ន្ធរូបិយវត្ថុ និងប្រព័ន្ធអត្រាប្តូរប្រាក់ក៏ពុំមានអត្ថិភាពឡើយនៅក្នុងពេលនោះ ។ ក្រោយពីរបបប៉ុលពតបានបញ្ចប់ភ្លាមនៅក្នុងឆ្នាំ១៩៧៩ ប្រតិបត្តិការពាណិជ្ជកម្មបានប្រព្រឹត្តទៅ ជាសំខាន់តាមរូបភាពនៃការដោះដូរទំនិញ ក្រៅពីនេះ ត្រូវបានទូទាត់ជាប្រាក់បរទេសនិងមាស ក្រោយមកទៀតត្រូវបានប្រើជាឯកតាគណនី មធ្យោបាយប្តូរប្រាក់ និងលិខិតូបករណ៍សញ្ច័យ ។ បន្ទាប់ពីការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញនៅឆ្នាំ១៩៨0 ប្រាក់រៀលត្រូវបានបោះផ្សាយ ហើយបានធ្វើចរាចរជារូបិយវត្ថុនីត្យានុកូលរបស់ប្រទេស ។

ការប្រើដុល្លារ និងប្រាក់បាតថៃ ត្រូវបានរីតត្បិតតាំងពីដំបូង ដោយសារចរិតលក្ខណៈសេដ្ឋកិច្ចបិទជិត ។ ដុល្លាររូបនីយកម្មបានកើនឡើងជាបន្តបន្ទាប់ ចាប់តាំងពីប្រទេសកម្ពុជាបើកទ្វារទៅរកពិភពខាងក្រៅ ។ ទីបញ្ចប់ ដុល្លារអាមេរិកនិងប្រាក់បាតថៃមានពាសពេញក្នុងទីផ្សារកម្ពុជា នៅពេលដែលរដ្ឋាភិបាលជំរុញឱ្យមានការវិនិយោគបរទេសនៅឆ្នាំ១៩៨៩ ទន្ទឹមនឹងការអនុវត្តន៍គោលនយោបាយទីផ្សារសេរី ហើយនឹងការមកដល់របស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNTAC) ដើម្បីដំណើរការសន្តិភាពនៅកម្ពុជាចាប់តាំងពីចុងឆ្នាំ១៩៩១ មក ។

ផលប៉ះពាល់នៃការជួបប្រទះពីអតីតកាលរបស់កម្ពុជា អាចត្រូវបានឃើញយ៉ាងច្បាស់នៅពេលមានការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីធ្វើកំណែទំរង់ប្រព័ន្ធធនាគារ ដែលកំពុងប្រឈមនឹងបញ្ហាទាំងឡាយបន្សល់ទុកពីរបបចាស់ ដូចជា ÷

-ហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម និងច្បាប់ស្ទើរតែពុំមាន

-ជំនឿទុកចិត្តក្នុងស្ថេរភាពសេដ្ឋកិច្ច និងរូបិយវត្ថុក្នុងស្រុកធ្លាក់ចុះខ្លាំង

-ការប្រើមាស ហើយបន្ទាប់មកប្រើដុល្លារធ្វើជាការរក្សាទ្រព្យសម្បត្តិ និងជាមធ្យោបាយដោះដូរមានជាទូទៅ

-ដោយសារជំនឿក្នុងវិស័យធនាគារមានការបាត់បង់យ៉ាងធំធេង សេដ្ឋកិច្ចជាសាច់ប្រាក់មានសកម្មភាពខ្លាំងក្លា ។

## មូលដ្ឋានច្បាប់សំរាប់ប្រតិបត្តិការរូបិយប័ណ្ណ

ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៧ មានគោលនយោបាយខិតខំប្រឹងប្រែងប្រើប្រាស់ដើមទុនបរទេសឱ្យមានប្រសិទ្ធភាពតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីអភិវឌ្ឍ

សេដ្ឋកិច្ច និងដើម្បីសំរួលគោលនយោបាយក្រៅប្រទេសរបស់រដ្ឋាភិបាលដែលមានបំណងជំរុញការធ្វើសមាហរណកម្មជាថ្មីរបស់ប្រទេសទៅក្នុងសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក ។ ស្របជាមួយនិន្នាការ ទូទៅនៅក្នុងសេដ្ឋកិច្ចទីផ្សារឆ្ពោះទៅរករបបពាណិជ្ជកម្មសេរី វិនិយោគបរទេសប្រកបដោយសេរីភាវូបនីយ កម្ម និងសេរីភាវូបនីយកម្មនៃលំហូរហិរញ្ញវត្ថុអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាបន្តរក្សាអនុវត្តគោលនយោបាយធ្វើអន្តរាគមន៍តិចតួចបំផុតក្នុងយន្តការគ្រប់គ្រងប្តូរប្រាក់ ។

**បទប្បញ្ញត្តិសំខាន់ៗដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់គឺ** ÷

-គ្មានការរឹតត្បិតលើការប្រើប្រាស់រូបិយប័ណ្ណនៅក្នុងប្រតិបត្តិការក្នុងស្រុក

-គ្មានការរឹតត្បិតលើប្រតិបត្តិការជារូបិយប័ណ្ណ ដែលរួមមានទាំងការទិញនិងការលក់រូបិយប័ណ្ណលើទីផ្សារប្តូរប្រាក់ ការផ្ទេរប្រាក់ ការទូទាត់អន្តរជាតិគ្រប់ប្រភេទ ក៏ដូចជាចលនាដើមទុនជារូបិយប័ណ្ណ ។ ប៉ុន្តែ ប្រតិបត្តិការទាំងនោះត្រូវតែអនុវត្តដោយឆ្លងតាមអន្តរការីប្រតិស្រុតិ ដោយធនាគារជាតិនៃកម្ពុជា លើកលែងតែអ្នកដំណើរដែលត្រូវធ្វើប្រតិវេទន៍នូវចំនួនទឹកប្រាក់ដែលមានទឹកប្រាក់លើសពី ១ម៉ឺនដុល្លារ (ប៉ុន្តែ មិនត្រូវបានរឹតត្បិតចំពោះការនាំយកមូលនិធិចូលក្នុងប្រទេសឡើយ)

-ការនាំចេញប្រាក់ចំណេញត្រូវទាមទារឱ្យធ្វើការផ្ទេរឆ្លងតាមរយៈអន្តរការីប្រតិស្រុតិ

-ការផ្ទេរចេញដើមទុនវិនិយោគ ភាគលាភ ប្រាក់ចំណេញ និងការប្រាក់អាចធ្វើបានដោយសេរីឆ្លងតាមរយៈប្រព័ន្ធធនាគារដែលត្រូវរាយការណ៍ឱ្យធនាគារជាតិនៃកម្ពុជា ប្រសិនបើចំនួនប្រាក់នៃការផ្ទេរមួយលើកៗ មានចំនួនដល់ ១០ម៉ឺនដុល្លារអាមេរិក

-ការវិនិយោគក្រៅប្រទេសដោយនិវេសជនកម្ពុជា ដែលមានទឹកប្រាក់លើសពី ១០ម៉ឺនដុល្លារ ត្រូវធ្វើប្រតិវេទន៍ទៅធនាគារជាតិនៃកម្ពុជាជាមុន (ប៉ុន្តែមិនត្រូវបានរឹតត្បិតឡើយ)

-ការនាំចូល ឬការនាំចេញមាសមិនទាន់កែច្នៃ ត្បូងថ្មមានតម្លៃមិនទាន់កែច្នៃ ឬលោហធាតុមានតម្លៃមិនទាន់កែច្នៃដទៃទៀត ត្រូវធ្វើប្រតិវេទន៍ជាមុនទៅធនាគារជាតិនៃកម្ពុជា (ប៉ុន្តែមិនត្រូវបានរឹតត្បិតឡើយ) ។ និវេសជន និងអនិវេសជន ត្រូវបានអនុញ្ញាតឱ្យបើកគណនីរូបិយប័ណ្ណនៅធនាគារនៅកម្ពុជា

-ធនាគារកណ្តាលអាចរៀបចំការលក់រូបិយប័ណ្ណដោយការដេញថ្លៃ ។

## របបគ្រប់គ្រងការប្តូរប្រាក់បច្ចុប្បន្ន

របបគ្រប់គ្រងការប្តូរប្រាក់បច្ចុប្បន្ននៅកម្ពុជាអាចត្រូវបានកំណត់ចរិតលក្ខណៈថាជារបបទ្វិអត្រា (Dual Rate) ដែល មានអត្រាផ្លូវការ និងអត្រាទីផ្សារ ។ អត្រាទីផ្សារត្រូវបានកំណត់ដោយទីផ្សារ ដែលជាអត្រាប្តូរអណ្តែតដោយសេរី ចំណែកឯអត្រាផ្លូវការត្រូវបានកំណត់ដោយអាជ្ញាធររូបិយវត្ថុ គឺធនាគារជាតិនៃ

កម្ពុជា ដោយផ្អែកលើមូលដ្ឋាននៃការអភិវឌ្ឍន៍អត្រាក្នុងទីផ្សារ ពោលគឺរក្សាគំលាតមួយសមស្របរវាងអត្រាទាំងពីរ ។ នោះមានន័យថា កម្ពុជាបានប្រកាន់យកគោលនយោបាយអត្រាប្តូរប្រាក់ទីផ្សារសេរី ដោយការកែតំរូវអត្រាប្តូរផ្លូវការទៅតាមចលនាក្នុងអត្រាទីផ្សារ ។ ចាប់ពីដើមឆ្នាំ១៩៩៤មក រដ្ឋាភិបាលបានបន្ថយគំលាតអត្រាប្រចាំថ្ងៃពី៥% មកនៅតិចជាង ២% ហើយចាប់ពីឆ្នាំ១៩៩៥តមក អត្រាប្តូរផ្លូវការមិនមានការខុសគ្នាលើឬក្រោម១% ពីអត្រាទីផ្សារមធ្យមឡើយ ។ វិធានការនេះត្រូវបានអនុវត្តក្នុងគោលបំណងការពារជញ្ជីងទូទាត់ ហើយធានាថាទុនបំរុងបរទេសមិនត្រូវបានគេប្រើប្រាស់ដើម្បីការពារអត្រាប្តូរប្រាក់មិនប្រាកដនិយម ។ ដើម្បីទប់ទល់ការឡើងចុះដ៏គំហុកនៃអត្រាប្តូរ ដែលជាសំខាន់បណ្តាលមកពីកត្តាចិត្តសាស្ត្រ ធនាគារជាតិនៃកម្ពុជាតែងបានប្រើប្រាស់ការលក់ដេញថ្លៃដុល្លារអាមេរិកដើម្បីស្រូបយកប្រាក់រៀលពីចរាចរ ពោលគឺធនាគារប្តូរជាននាធ្វើអន្តរាគមន៍ដើម្បីទប់ទល់សម្ពាធធ្លាក់ចុះនៃតំលៃប្រាក់រៀលទេ លើកលែងតែក្នុងកាលៈទេសៈដែលចលនាទីផ្សារកើតមានការបាត់សណ្តាប់ធ្នាប់ ។ ដូច្នេះហើយបានជាចាប់ពីចុងឆ្នាំ១៩៩៨តមក កម្ពុជាទទួលបានអំណោយផលនៃស្ថេរភាពនយោបាយនិងសេដ្ឋកិច្ច ធនាគារជាតិពុំចាំបាច់ធ្វើអន្តរាគមន៍លក់ដេញថ្លៃដុល្លារសំរាប់កម្មវត្ថុស្រូបប្រាក់រៀលទៀតដែរ ផ្ទុយទៅវិញបែរជាបានទិញដុល្លារដើម្បីបង្គរទុនបំរុងអន្តរជាតិសំរាប់ប្រទេសថែមទៀតផង ។

រដ្ឋាភិបាលបានអនុម័តយល់ព្រមទទួលកាតព្វកិច្ចនៃមាត្រាVIII ចំណុចទី២ ទី៣ និងទី៤នៃលក្ខន្តិកៈរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចាប់តាំងពីថ្ងៃទី១ មករា ឆ្នាំ២០០២ ។ ប្រការនេះ បង្ហាញនូវសញ្ញាមួយយ៉ាងច្បាស់ពីការប៉ុនប៉ងដ៏មោះមុតក្នុងការធ្វើសមាហរណកម្មនៃសេដ្ឋកិច្ចកម្ពុជាទៅក្នុងសហគមន៍អន្តរជាតិ ។

## ដុល្លារូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជា

ប្រទេសកម្ពុជាអាចត្រូវបានចាត់ទុកថា ជាប្រទេសមួយដែលមានករណីពិសេសនៅក្នុងតំបន់ ពីព្រោះជាប្រទេសមានដុល្លារូបនីយកម្មខ្ពស់ ។ ការប្រើប្រាស់ដុល្លារអាមេរិកយ៉ាងទូលំទូលាយជាឯកតារូបិយវត្ថុ បានធ្វើឱ្យដុល្លារអាមេរិកបំពេញមុខងារទន្ទឹមនឹងប្រាក់រៀលជា ÷

-ឧបករណ៍វាស់តម្លៃ (ថ្លៃទំនិញ និងសេវាកម្ម ជារឿយៗត្រូវបានចារិកជាដុល្លារអាមេរិក)

-ឧបករណ៍ទូទាត់ (ប្រតិបត្តិការមានទឹកប្រាក់ខ្ពស់ស្ទើរតែទាំងអស់ត្រូវបានធ្វើជាសាច់ប្រាក់ដុល្លារ)

-ឧបករណ៍សន្សំសំរាប់ប្រជាពលរដ្ឋ ។

ទិន្នន័យរូបិយវត្ថុដែលបានទទួលពីប្រភពផ្លូវការ បង្ហាញថាប្រាក់បញ្ញើជារូបិយប័ណ្ណនៅក្នុងប្រព័ន្ធធនាគារជណ្តើមសមាមាត្រប្រហែល៦០%នៃរូបិយវត្ថុទូទៅ ($M_2$) ហើយចំណែកនៃរូបិយប័ណ្ណមាន ៩៥% លើសរុបប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ និង៩៨% លើសរុបឥណទានរបស់ធនាគារពាណិជ្ជ ។

បន្ថែមពីលើចំនួនដ៏ធំនៃទ្រព្យសកម្មចារិកជាដុល្លារអាមេរិកដែលមាននៅក្នុងស្ថិតិជាផ្លូវការ ចំនួន

សាច់ប្រាក់ដុល្លារដែលមិនអាចគណនាបានកំពុងធ្វើចរាចរយ៉ាងទូលំទូលាយទន្ទឹមនឹងប្រាក់រៀល ។ ឥឡូវនេះ អាជ្ញាធរកំពុងពិនិត្យពិចារណានូវការអភិវឌ្ឍន៍យន្តការសមស្របមួយដើម្បីប៉ាន់ស្មានទំហំនេះ ។

**បញ្ហានៃការកំណត់និយមន័យអត្រាប្តូរនៃរូបិយវត្ថុក្នុងស្រុកក្នុងបរិបទនៃសេដ្ឋកិច្ចដុល្លាររូបនីយកម្ម**

អត្រាប្តូរនាមនាមគឺជាថ្លៃធៀប ដែលមានន័យថាជារង្វាស់នៃតម្លៃរូបិយវត្ថុមួយធៀបនឹងរូបិយវត្ថុមួយទៀត ។ នៅស្ទើរគ្រប់ប្រទេសទាំងអស់ អត្រាប្តូរនាមនាមត្រូវបានគណនាតាមរូបិយវត្ថុក្នុងស្រុកធៀបនឹងអត្រាប្តូរនាមនាមនៃរូបិយប័ណ្ណមួយឬចង្កោមមួយនៃរូបិយប័ណ្ណ ។ ឧទាហរណ៍ ដូចជាតម្លៃធៀបនៃរូបិយវត្ថុក្នុងស្រុកធៀបនឹងរូបិយវត្ថុជាទុនបំរុង ដែលជាអាទិ៍មានដុល្លារអាមេរិក ឬប្រាក់យេន ។ ក្នុងករណីប្រទេសកម្ពុជា បញ្ហានៃការកំណត់និយមន័យអត្រាប្តូរនាមនាម គឺមិនងាយស្រួលឡើយ ពីព្រោះដុល្លាររូបនីយកម្មក៏រីកធំបានដើរទន្ទឹមនឹងការបោះផ្សាយរូបិយវត្ថុក្នុងស្រុក ។ ដូច្នោះ ដោយសារដុល្លាររូបនីយកម្មមានបញ្ហាចោទឡើងថា តើរូបិយវត្ថុណាមួយជារូបិយវត្ថុ "ក្នុងស្រុក" មានប្រសិទ្ធភាពរបស់កម្ពុជា ?

ជាក់ស្តែង អត្រាប្តូរនាមនាមប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ត្រូវបានរាយការណ៍យ៉ាងទូលំទូលាយនៅក្នុងរបាយការណ៍ស្ថិតិ និងសារពតិមានហិរញ្ញវត្ថុ ។ ពិតហើយថាតម្លៃនៃអត្រាប្តូរនេះឆ្លុះបញ្ចាំងក្នុងកំរិតណាមួយនូវលក្ខខណ្ឌតំរូវការ និងការផ្គត់ផ្គង់នៅក្នុងទីផ្សារសំរាប់ប្រាក់រៀលនិងដុល្លារអាមេរិក ។ ប៉ុន្តែទីផ្សារនេះមានទំហំតូចតាចទេ ហើយអត្រាប្តូរនេះត្រូវបានកំណត់ជាសំខាន់ដោយផ្អែកលើលក្ខខណ្ឌសេដ្ឋកិច្ចអន្តរជាតិ ព្រមទាំងលក្ខខណ្ឌចិត្តសាស្ត្រ សង្គម និងនយោបាយ ។

តម្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបានប្រែប្រួលយ៉ាងស្រួចស្រាវ (ប៉ុន្តែជាបណ្តោះអាសន្ន) ចាប់តាំងពីដើមឆ្នាំ១៩៩៣មក ។ តម្លៃប្រាក់រៀលបានធ្លាក់ចុះយ៉ាងខ្លាំងនៅដើមឆ្នាំ១៩៩៣ (រហូតដល់ ៤២០០រៀលក្នុង១ដុល្លារ) បន្ទាប់មកបានឡើងថ្លៃវិញ ហើយនឹងមានស្ថេរភាពបង្គួរ (រវាង ២៦០០ និង ២៨០០រៀលក្នុង១ដុល្លារ) ក្នុងកំឡុងឆ្នាំ ១៩៩៤-១៩៩៦ នៅពេលដែលស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានស្តារឡើងវិញ ព្រមជាមួយគោលនយោបាយហិរញ្ញវត្ថុក៏បានល្អប្រសើរឡើងដែរ ។ ប៉ុន្តែអត្រាប្តូរប្រាក់នៅតែស្ថិតនៅក្នុងរង្វង់នៃការប៉ះទង្គិចធំធេង ហើយវិបត្តិហិរញ្ញវត្ថុនៅក្នុងបណ្តាប្រទេសជិតខាងក៏បានរួមចំណែកឱ្យមានការធ្លាក់ថ្លៃនៃប្រាក់រៀលនៅឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៨ ។ ប្រាក់រៀលបានធ្លាក់ថ្លៃប្រហែល ២៧% ធៀបនឹងដុល្លារអាមេរិកនៅចន្លោះ ខែកក្កដា ឆ្នាំ ១៩៩៧ និងខែតុលា ឆ្នាំ ១៩៩៨ ។

ប៉ុន្តែ នៅមានជំរើសមួយផ្សេងទៀតផងដែរដែលនិយាយបានថា ដុល្លារអាមេរិកគឺជារូបិយវត្ថុ "ក្នុងស្រុក" របស់កម្ពុជា ព្រោះថា ដោយថ្លៃទំនិញនាំចូលមកកម្ពុជាបានគិតជាដុល្លារអាមេរិក ហើយថ្លៃទំនិញទាំងនេះនៅក្នុងទីផ្សារក្នុងស្រុកត្រូវបានកំណត់ជាដុល្លារអាមេរិក ដូច្នេះការប្រែប្រួលតម្លៃនៃអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមិនបានចូលរួមក្នុងការកំណត់ថ្លៃនៃការនាំចូលរបស់ទីផ្សារកម្ពុជាទេ ។ ដូចគ្នានេះដែរ ដោយថ្លៃទំនិញនាំចេញពីកម្ពុជាត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារពិភពលោក ដូច្នេះការ

ប្រែប្រួលតម្លៃអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកក៏មិនមានផលប៉ះពាល់ដល់ថ្លៃឡើយ ។ នៅក្នុងស្ថានភាពដូនេះ សូម្បីតែបច្ចេកសព្ទ "អត្រាប្តូរប្រាក់" ក៏មិនមានលក្ខណៈសមស្របនៅក្នុងបរិបទរបស់កម្ពុជាដែរ ហើយឥទ្ធិពលនៃដុល្លារូបនីយកម្មអាចឱ្យចាត់ទុកបានថា កម្ពុជាកំពុងប្រកាន់យករបបអត្រាប្តូរប្រាក់ថេរមួយ ។ ជាលទ្ធផលគឺបានធ្វើឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរសំរាប់សេដ្ឋកិច្ចកម្ពុជា សំរាប់ការប្រកួតប្រជែង ពីព្រោះវាធ្វើឱ្យបាត់លទ្ធភាពរបស់ប្រទេសក្នុងការកែតំរូវ បើពេលណាមានការធ្លាក់ថ្លៃនៃរូបិយវត្ថុរបស់បណ្តាប្រទេសជិតខាង ។ ទោះជាយ៉ាងនេះក្តី ក៏បដិដុល្លារូបនីយកម្មនៅបានផ្តល់អត្ថប្រយោជន៍ទន្ទឹមនឹងការខាតបង់នេះផងដែរ ។

## អត្ថប្រយោជន៍ និងបរិយាកាសនៃដុល្លារូបនីយកម្ម

ការប្រើដុល្លារអាមេរិកបាននាំឱ្យកម្ពុជាមានគុណសម្បត្តិមួយចំនួន។

### អត្ថប្រយោជន៍នៃដុល្លារូបនីយកម្ម :

-ជួយប្តូរទំលាប់របស់សាធារណជនពីការចាយមាសទៅជាការចាយធនប័ត្រដែលកំណត់ជាដុល្លារអាមេរិក

-ដុល្លារអនុញ្ញាតឱ្យប្រជាពលរដ្ឋរក្សាបាននូវអំណាចទិញរបស់វា

-ដុល្លារូបនីយកម្មកើតខ្ពស់រហូតមកដល់ពេលនេះបានផ្តល់នូវទ្រនាប់ទប់ទល់និងវិបត្តិរូបិយវត្ថុ និងវិបត្តិធនាគារដែលបានផ្ទុះឡើងកាលពីខែកក្កដា ឆ្នាំ ១៩៩៧

-ប្រាក់បញ្ញើជារូបិយប័ណ្ណជំរុញឱ្យមានអានុភាពហិរញ្ញវត្ថុ ។ សញ្ច័យក្នុងស្រុកដែលបានវាស់ស្ទង់តាមចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណនៅក្នុងប្រព័ន្ធធនាគារបានកើនឡើងយ៉ាងខ្លាំង ចាប់តាំងពីកម្ពុជាបានបើកចំហសេដ្ឋកិច្ចរបស់ខ្លួននៅឆ្នាំ ១៩៩៣ ។ តាមការប្រៀបធៀប សញ្ច័យជារូបិយវត្ថុក្នុងស្រុកបានកើនឡើងផងដែរ ប៉ុន្តែមានល្បឿនយឺតជាងយ៉ាងច្រើន។

-អត្ថិភាពនៃគណនីជាដុល្លារនៅក្នុងធនាគារក្នុងស្រុក ជួយសំរួលនូវសមាហរណកម្មនៃទីផ្សារក្នុងស្រុកទៅក្នុងទីផ្សារពិភពលោក ហើយបន្ថយនូវចំណាយប្រតិបត្តិការហិរញ្ញវត្ថុ ។ ការប្រើដុល្លារជំនួសរូបិយវត្ថុជាតិ ផ្តល់ឱកាសឱ្យប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុកពង្រីកអន្តរការិយកម្ម តាមរយៈការរាំងទិវេសជនពីការដាក់សញ្ច័យជារូបិយប័ណ្ណរបស់ពួកគេក្នុងគណនីក្រៅប្រទេស

-រូបិយវត្ថុមានស្ថេរភាពជំរុញឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងបរិដ្ឋានពាណិជ្ជកម្មអាចព្យាករណ៍បាន ដែលមានសារៈសំខាន់បំផុតសំរាប់កម្ពុជា ពិសេសតាមរយៈទស្សនៈរបស់វិនិយោគិនអន្តរជាតិ ។

### ហេតុផលដែលធ្វើឱ្យមានការចេញចិត្តប្រើដុល្លារអាមេរិក ÷

-សេដ្ឋកិច្ចបានឆ្លងកាត់រយៈពេលមានអតិផរណាខ្ពស់ និងលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលមានអស្ថេរភាព ភាពមិនប្រាកដប្រជាអំពីការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ចនៅតែគ្របដណ្តប់ និង

-ប្រាក់រៀលមានហានិភ័យអត្រាប្តូរប្រាក់ខ្ពស់បំផុត ។

**បរិយាធាននៃដុល្លារូបនីយកម្ម :**

គុណវិបត្តិមានច្រើន ដូចតទៅ ÷

- ដុល្លារូបនីយកម្មបង្កើតឱ្យមានគុណវិបត្តិចំពោះសាធារណជនដែលមានប្រាក់ចំណូលជារូបិយវត្ថុក្នុងស្រុក
- តំរូវការរូបិយវត្ថុក្នុងស្រុកទាប ហើយទ្រព្យអកម្មក្នុងស្រុកទាប មានន័យថាមានលទ្ធភាពតិចតួចសំរាប់គោលនយោបាយរូបិយវត្ថុក្នុងការធ្វើសកម្មភាព ។ ការប្រើដុល្លារអាមេរិកជំនួសរូបិយវត្ថុធ្វើឱ្យអន្តរាយដល់ការប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាពរបស់គោលនយោបាយរូបិយវត្ថុ ។ ដោយហេតុថា ឥណទានរបស់ធនាគារពាណិជ្ជ និងប្រាក់បញ្ញើរបស់អតិថិជនត្រូវបានកំណត់ជារូបិយប័ណ្ណយ៉ាងទូលំទូលាយធនាគារជាតិនៃកម្ពុជាមានឱកាសតិចតួចដើម្បីអភិវឌ្ឍន៍ឧបករណ៍គោលនយោបាយរូបិយវត្ថុ ។ លើសពីនេះទៅទៀត ធនាគារជាតិនៃកម្ពុជាមិនអាចបំពេញតួនាទីរបស់ខ្លួនជាអ្នកឱ្យខ្ចីចុងក្រោយដល់ធនាគារដែលប្រឈមមុខនឹងបញ្ហាសាច់ប្រាក់ងាយស្រួលទេ
- ដោយសារមានគុណភាពជារូបិយវត្ថុបំរុង ដុល្លារអាមេរិកត្រូវបានសាធារណជនពេញចិត្តជាងប្រាក់រៀល ហើយធ្វើឱ្យមានផលអាក្រក់ដល់ការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជនលើប្រាក់រៀល
- បើសាច់ប្រាក់ដុល្លារអាមេរិកនៅតែមាននៅក្នុងហោប៉ៅរបស់ប្រជាពលរដ្ឋកម្ពុជា ធនាគារជាតិនៃកម្ពុជា ក៏ដូចជារដ្ឋាភិបាល និងសេដ្ឋកិច្ចកម្ពុជាទាំងមូល នឹងត្រូវបាត់បង់ប្រយោជន៍ដ៏ធំដែលត្រូវទទួលបានពីកំរៃការប្រាក់ ។ ការរក្សាទុកដុល្លារអាមេរិក មានន័យថា ប្រជាពលរដ្ឋកម្ពុជាធ្វើហិរញ្ញប្បទានដោយប្រយោលដល់រដ្ឋាភិបាលអាមេរិក តាមរយៈធនាគារសហព័ន្ធសអាមេរិក (Seigno- riaze)
- ទំហំសាច់ប្រាក់ងាយស្រួលជាដុល្លារអាមេរិកនៅក្នុងចរាចរណ៍ដ៏ច្រើន ហើយដែលគេមិនបានដឹងនឹងធាចជាការសំរួលដល់សកម្មភាពលាងលុយកខ្វក់
- ចំពោះចំណាយក្នុងស្រុកដែលត្រូវបានកំណត់តម្លៃជាដុល្លារអាមេរិក កម្ពុជាអាចបាត់នូវភាពប្រកួតប្រជែងខាងការនាំចេញរបស់ខ្លួន ប្រសិនបើចំណាយនោះមិនទាបជាងគេដាច់ខាតទេនោះ
- តំរូវការរូបិយវត្ថុក្នុងស្រុកទាប បង្អាក់ធនាគារកណ្តាលនៅក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីបង្កើនទុនបំរុងអន្តរជាតិ ។

**គោលនយោបាយបដិដុល្លារូបនីយកម្ម**

ជារួម ពុំមានភស្តុតាងជាក់ស្តែងណាមួយដែលថា បរិយាទានមានទំហំធំជាងអត្ថប្រយោជន៍នៃ

ដុល្លារូបនីយកម្មនោះទេ ។ តាមមូលបទនេះ រដ្ឋាភិបាលបានទទួលព្រមឱ្យមានការប្រើប្រាស់ដុល្លារអាមេរិក នៅក្នុងសេដ្ឋកិច្ច ហើយមានការត្រិះរិះជាគោលដៅរយៈពេលមធ្យមសំរាប់ធ្វើបដិដុល្លារូបនីយកម្ម ដែលចាប់ផ្តើមជាមួយនឹងជំហានលើកទឹកចិត្តឱ្យមានការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ។

ប៉ុន្តែបរិដ្ឋានអស្ថេរភាពរារាំងការខិតខំប្រឹងប្រែង ដើម្បីបង្កើនឱ្យមានការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ជាពិសេសចំពោះសញ្ញ័យ ។ មានការលំបាកក្នុងការធ្វើបដិដុល្លារូបនីយកម្ម បើបរិដ្ឋានម៉ាក្រូសេដ្ឋកិច្ចនៅផុយស្រួយបំផុត ហើយតម្លៃប្រាក់រៀលនៅពុំទាន់មានស្ថេរភាពនៅឡើយទេនោះ ។ លើសពីនេះទៅទៀត ពេលដែលប្រជាពលរដ្ឋនៅទទួលភាពកក់ក្តៅនិងងាយស្រួលក្នុងការប្រើប្រាស់ដុល្លារអាមេរិក វាជាការលំបាកណាស់ក្នុងការជំនះឱ្យគេបោះបង់ហើយវិលមករកប្រាក់រៀល ទោះបីជាគ្មានសម្ពាធទៅលើអតិផរណា និងការចុះថ្លៃអត្រាប្តូរប្រាក់ក៏ដោយ ។ ចាំបាច់ត្រូវប្រើពេលយូរដើម្បីកែតំរូវឥរិយាបទរបស់ប្រជាពលរដ្ឋ ។

វិធានការរដ្ឋបាលចាប់បង្ខំឱ្យមានការផ្លាស់ប្តូរ ត្រូវបានចាត់ទុកថាជាការបំផ្លាញដល់ការខិតខំប្រឹងប្រែងធ្វើឱ្យសេដ្ឋកិច្ចមានស្ថេរភាព ។ បើបញ្ហាជាមូលដ្ឋានមិនត្រូវបានដោះស្រាយទេ ការជំនះអនុវត្តន៍វិធានការនេះផ្តល់លទ្ធផលឱ្យកើតមានសកម្មភាពផ្សារងងឹត ដែលតំរូវឱ្យមានបែបបទរដ្ឋបាលនិងការកែតំរូវជាច្រើន ។

ធនាគារជាតិនៃកម្ពុជាយល់ច្បាស់ថា ស្ថេរភាពហិរញ្ញវត្ថុយូរអង្វែង គឺជាគន្លឹះសំរាប់លុបបំបាត់ការប្រើជំនួសរូបិយវត្ថុ ហើយនឹងការបង្កើតប្រព័ន្ធអន្តរការិយកម្មហិរញ្ញវត្ថុ ដែលចារិកជារូបិយវត្ថុក្នុងស្រុក ។ ប៉ុន្តែជាក់ស្តែង ការស្តារទំនុកទុកចិត្តរបស់សាធារណជន និងការអនុវត្តន៍គោលនយោបាយបដិដុល្លារូបនីយកម្មចាំបាច់ត្រូវមានស្ថេរភាពសង្គម និងនយោបាយ ។ នៅពេលដែលលក្ខខណ្ឌនេះនឹងត្រូវបានបំពេញ បដិដុល្លារូបនីយកម្មនឹងត្រូវតែបានអនុវត្តយ៉ាងរលូន ដើម្បីកុំឱ្យមានឥទ្ធិពលទៅលើសកម្មភាពសេដ្ឋកិច្ចដែលកំពុងប្រព្រឹត្តទៅ ។ តាមទស្សនវិស័យនេះ ធនាគារជាតិនៃកម្ពុជា ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀតត្រូវចាប់ផ្តើមទៅលើបញ្ហាដូចតទៅ ÷

- ប្រមូលផ្តុំមូលនិធិចារិកជារូបិយប័ណ្ណទាំងអស់របស់រដ្ឋាភិបាល ដែលពីមុនមកបានរក្សាទុកនៅក្នុងធនាគារពាណិជ្ជមួយចំនួន ឱ្យចូលទៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅធនាគារជាតិនៃកម្ពុជា ។
- ព្យាយាមអនុវត្តគោលនយោបាយហិរញ្ញវត្ថុតឹងរ៉ឹងដែលបានគ្រោងឡើង ដើម្បីចៀសវាងការធ្វើហិរញ្ញប្បទានរូបិយវត្ថុដល់ថវិកា ។ ជាលទ្ធផល កំណើនសាច់ប្រាក់ងាយស្រួលត្រូវបានបន្ថយ ហើយអតិផរណាស្ថិតនៅក្នុងកំរិតគ្រប់គ្រងបាន ដែលពីនោះអាចបង្កើនផងដែរនូវស្ថេរភាពអត្រាប្តូរប្រាក់ ។
- ការទូទាត់ប្រាក់បៀវត្ស ការប្រមូលចំណូលរបស់រដ្ឋាភិបាល ហើយនឹងការកំណត់ថ្លៃចាំបាច់ត្រូវប្រព្រឹត្តទៅជាប្រាក់រៀល ។

-ប្រយុទ្ធនឹងអតិផរណា ។

-រក្សាតំលៃរូបិយវត្ថុជាតិនៅក្រៅប្រទេស ។

-ព្យាយាមកំណត់អត្រាការប្រាក់ពិតវិជ្ជមានសំរាប់ប្រាក់បញ្ញើជាប្រាក់រៀល ។

-ព្យាយាមបង្កើនទុនបំរុងអន្តរជាតិគ្រប់គ្រាន់ ដើម្បីទប់ទល់វិបត្តិនិងការវាយប្រហារដែលអាចកើតមាន ។

-ពង្រឹងការត្រួតពិនិត្យធនាគារ ដើម្បីជំរុញឱ្យមានជំនឿទុកចិត្តរបស់សាធារណជនឡើងវិញនៅក្នុងប្រព័ន្ធធនាគារ ។

ការអនុវត្តន៍គោលនយោបាយបដិដុល្លារូបនីយកម្ម ពុំមែនជាបញ្ហាដែលប្រើបទប្បញ្ញត្តិរឹងស្លូកនោះទេ តែទាមទារការបង្កើតបរិដ្ឋានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈច្បាស់លាស់សំរាប់អត្ថប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងការវិលទៅរកប្រាក់រៀល ។ ដំណើរការបដិដុល្លារូបនីយកម្មចាំបាច់ត្រូវបានអនុវត្តដោយមិនធ្វើឱ្យខូចខាតដល់កំណើនសកម្មភាពសេដ្ឋកិច្ច ។

# បញ្ជីឈ្មោះធនាគារពាណិជ្ជ

| | ធនាគារនិងអាសយដ្ឋាន | ទូរស័ព្ទនិងទូរសារ |
|---|---|---|
| ១ | **ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់**<br># 97-99, មហាវិថីព្រះនរោត្តម, បឹងរាំង, ដូនពេញ | ទូរស័ព្ទ : 720434-720436<br>Fax : (855-23)720435 |
| ២ | **ធនាគារ កម្ពុជាអាស៊ី ចំកាត់**<br># 320A-320B, មហាវិថីព្រះមុនីវង្ស, សង្កាត់បឹងរាំង, ដូនពេញ | ទូរស័ព្ទ : 722105,363111<br>Fax: (855-23)426628 |
| ៣ | **ធនាគារ កាណាឌីយ៉ា ចំកាត់**<br># 265-267-269, វិថីព្រះអង្គឌួង, វត្តភ្នំ , ដូនពេញ | ទូរស័ព្ទ : 215284,215286<br>Fax : (855-23) 427064 |
| ៤ | **ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់**<br># 26, មហាវិថីព្រះមុនីវង្ស, ផ្សារថ្មី II, ដូនពេញ | ទូរស័ព្ទ : 426145,,213601,213602<br>Fax: (855-23) 426116 |
| ៥ | **ធនាគារ មេគង្គកម្ពុជា មហាជន** ទទួលខុសត្រូវមានកំរិត<br># 01, វិថីក្រមួនសរ, ផ្សារថ្មី I, ដូនពេញ | ទូរស័ព្ទ : 217112<br>Fax: (855-23) 217122 |
| ៦ | **ធនាគារ កម្ពុជាសាធារណៈ ចំកាត់**<br># 23, ផ្លូវក្រមួនសរ, ផ្សារថ្មី II, ដូនពេញ | ទូរស័ព្ទ :217686<br>Fax: (855-23) 426068 |
| ៧ | **ក្រេឌីត អាហ្គ្រីកូល ឥណ្ឌូស៊ុយអេស៍ សាខាកម្ពុជា**<br># 70, មហាវិថីព្រះនរោត្តម, បឹងរាំង, ដូនពេញ | ទូរស័ព្ទ : 427233, 428112<br>Fax: (855-23) 214481 |
| ៨ | **ធនាគារ ពាណិជ្ជកម្មទីមួយ សាខាភ្នំពេញ**<br># 263, វិថីព្រះអង្គឌួង, វត្តភ្នំ, ដូនពេញ | ទូរស័ព្ទ : 210027, 210028<br>Fax: (855-23) 210029 |
| ៩ | **ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា**<br># 03 , ផ្លូវ 53 -114, ផ្សារថ្មី I , ដូនពេញ | ទូរស័ព្ទ :724466,723866 722466, 723466<br>Fax: (855-23) 426108, 426410 |
| ១០ | **ធនាគារ គ្រុងថៃ ចំកាត់ មហាជន សាខាភ្នំពេញ**<br># 149 ផ្លូវ215 , ផ្សារដេប៉ូ I, ទួលគោក | ទូរស័ព្ទ : (023) 366005<br>Fax: (855) –23 428737 |
| ១១ | **ធនាគារ មេយប៊ែង សាខាភ្នំពេញ**<br># 03 , ផ្លូវ114, ផ្សារថ្មី I, ដូនពេញ | ទូរស័ព្ទ :(023) 217771,217772,210225<br>Fax: (023) 210099 |
| ១២ | **សាជីវកម្មធនាគារសិង្ហបុរី ចំកាត់**<br># 68, វិថី សម្ដេចប៉ាន, បឹងរាំង, ដូនពេញ | ទូរស័ព្ទ :(023) 217771,211211,217772<br>Fax: (023) 212121 |
| ១៣ | **ធនាគារ សហពាណិជ្ជ ក.អ**<br># 61 , ផ្លូវ130 , ផ្សារចាស់, ដូនពេញ | ទូរស័ព្ទ: (023) 427995<br>Fax: (855) -23 427997 |
| ១៤ | **ធនាគារ វឌ្ឍនៈ**<br># 89, មហាវិថីព្រះនរោត្តម, បឹងរាំង, ដូនពេញ | ទូរស័ព្ទ :(023) 212727<br>Fax: (023) 216687 |

## ធនាគារ ឯកទេស

| | | |
|---|---|---|
| ១ | **ធនាគារ អភិវឌ្ឍន៍ជនបទ** ឯកទេស<br># 5,វិថីព្រះអង្គអេង, វត្តភ្នំ, ដូនពេញ | ទូរស័ព្ទ: (023) 982434,982408 |
| ២ | **ធនាគារ អេស៊ីលីដា** ឯកទេស<br># 28, មហាវិថីម៉ៅសេទុង, បឹងត្របែក,ចំការមន | ទូរស័ព្ទ: (023) 210812,364619,214634<br>Fax: (023) 364614 |
| ៣ | **ធនាគារឯកទេសម៉េងហេង អេសអឹមអ៊ី**<br># 74, មហាវិថីព្រះនរោត្តម, ជ័យជំនះ, ដូនពេញ | ទូរស័ព្ទ: (023) 219243,219245<br>Fax: (023) 219185 |
| ៤ | **ធនាគារ ឯកទេស កសិកម្ម_ឧស្សាហកម្មកម្ពុជា**<br># 83,មហាវិថីព្រះនរោត្តម,បឹងរាំង, ដូនពេញ | ទូរស័ព្ទ: (023) 217750,218667<br>Fax: (023) 217751 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

| | | |
|---|---|---|
| ១ | **ឥណទានមូលដ្ឋាន ជនបទ** EMT<br># 72-74, ផ្លូវ៥៩៨, បឹងកក់II,ទួលគោក | ទូរស័ព្ទ: (023) 362913,880942 |
| ២ | **ហត្ថាកសិករ**<br>ផ្លូវលេខ 4,ភូមិពាលញែក I,ឃុំផ្ទះព្រៃ,ស្រុកសំពៅមាស,<br>ខេត្តពោធិសាត់ | ទូរស័ព្ទ: (052) 95144,012 841887<br>Fax: (052) 951404<br>E-mail: kaksekar@camintel.Com |
| ៣ | **មីក្រូហិរញ្ញវត្ថុ ចំការ កម្ពុជា**<br># 75 Eo,មហាវិថីម៉ៅសេទុង,បឹងកេងកង III ,ចំការមន | ទូរស័ព្ទ: (023) 362885 016 912492<br>016 987919 |

## ការិយាល័យតំណាង

| | | |
|---|---|---|
| ១ | **ស្តង់ដាឆាធើរ៉េត**<br># សណ្ឋាគារមីកាសា ៣១៣ ផ្លូវព្រះស៊ីសុវត្ថិ ភ្នំពេញ | ទូរស័ព្ទ: (023) 426685,212732 |

## LIST OF COMMERCIAL BANKS

| | | |
|---|---|---|
| 01 | **ADVANCED BANK OF ASIA Ltd.**<br># 97-99,Preah Norodom Blvd, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, **Cambodia** | Tel: 720434<br>Fax : (855-23) 720435 |
| 02 | **CAMBODIA ASIA BANK Ltd.**<br># 252, Preah Monivong Blvd, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, **Cambodia** | Tel. (855-23) 722105, 363111<br>Fax: (855-23) 426628 |
| 03 | **CANADIA BANK Ltd.**<br># 265-267-269,Preah Ang Duong St.SangkatWattPhnom, Khan Daun Penh, Phnom Penh, **Cambodia** | Tel. :(855-23) 215284,215286<br>Fax : (855-23) 427064 |
| 04 | **CAMBODIAN COMMERCIAL BANK Ltd.**<br># 26, Preah Monivong Blvd, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, **Cambodia** | Tel. 426145, 426639,213601, 213602<br>Fax: (855-23) 426116 |
| 05 | **CAMBODIA MEKONG BANK Public Ltd.**<br># 01,Kramoun Sar St. Sangkat Phsar Thmey I, Khan Daun Penh, Phnom Penh, **Cambodia** | Tel : 217114, 217115<br>Fax : (855-23) 217122 |
| 06 | **CAMBODIAN PUBLIC BANK**<br># 23,Kramoun Sar St. Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, **Cambodia** | Tel. 723664<br>Fax : (855-23) 426068 |
| 07 | **CREDIT AGRICOLE INDOSUEZ Cambodia branch**<br># 70,Preah Norodom Blvd, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, **Cambodia** | Tel. 427233,428112<br>Fax : (855-23) 214481 |
| 08 | **FIRST COMMERCIAL BANK Phnom Penh Branch**<br># 263,Preah Ang Duong St. Sangkat Watt Phnom, Khan Daun Penh, Phnom Penh, **Cambodia** | Tel. 210027<br>Fax : (855-23) 210029 |
| 09 | **FOREIGN TRADE BANK OF CAMBODIA**<br># 03,Street 53-114,Sangk.Phsar Thmey I, Khan Daun Penh, Phnom Penh, **Cambodia** | Tel.:724466,723866,722466,723466<br>Fax : (855-23) 426108,425410 |
| 10 | **KRUNG THAI BANK PUBLIC Co.Ltd. P.Penh Branch**<br>#149,215 rd. Sangkat Phsar Depo I, Khan Tuolkok Phnom Penh, **Cambodia**. | Tel :(855-23) 366005<br>Fax :(855-23) 428737 |
| 11 | **MAY BANK PHNOM PENH BRANCH**<br># 03,Street 114 (Kramoun Sar) Sangkat Phsar Thmey I, Khan Daun Penh, Phnom Penh, Cambodia . | Tel. : 210123/210233/210255<br>Fax:(855-023)210099 |
| 12 | **SINGAPORE BANKING CORPORATION**<br># 68,Samdechpann St. Sangkat Boeung Raing, Khan Daun Penh, Phnom Penh, **Cambodia** | Tel. 427555,723366,723337<br>Fax : (855-23) 427277 |
| 13 | **UNION COMMERCIAL BANK PLC.**<br># 61, 130 Road, Sangkat Phsar Chass, Khan Daun Penh, Phnom Penh, **Cambodia** | Tel. : 427995<br>Fax : (855-23) 427997 |
| 14 | **VATTANAC BANK**<br># 89, Preah Norodom Blvd, Sangkat Boeung Raing, Khan Daun Penh Cambodia. | Tel. : (023) 212 727<br>Fax : (023) 216 687 |

## SPECIALIZED BANK

| | | |
|---|---|---|
| 1 | **RURAL DEVELOPMENT BANK ( Specialized Bank )**<br># 5, Preah Ang Eng St. Sangkat Watt Phnom Khan Daun Penh<br>Phnom Penh, **Cambodia .** | Tel : 982434, 982408 |
| 2 | **ACLEDA BANK LIMITED ( specialized Bank )**<br>#28, Mao Tse Tung Blvd. Sangkat Boeung Trabek Khan Chamar Mon, Phnom Penh, **Cambodia** | Tel (855-23) 210 812, 364 619, 214 634<br>Fax: (855-23) 364 614 |
| 3 | **PENG HENG S.M.E. BANK Ltd. ( specialized Bank )**<br>#74, Norodom Blvd. Sangkat Chey Chumneas, Khan DaunPenh., Phnom Penh, **Cambodia** | Tel (855-23) 21 9243,219245<br>Fax: (855-23) 219185 |
| 4 | **Cambodia Agriculture Industrial Specialized Bank**<br># 87, Preah Norodom Blvd, Sangkat Boeung Raing, Daun Penh<br>Cambodia. | Tel: (023) 217750 218667<br>Fax: (023) 217751 |

## MICROFINANCE INSTITUTION

| | | |
|---|---|---|
| 1 | **Ennatien Moulethan Tchonnebat "EMT"(Micro Finance)**<br>#72-74,598St. Sangkat Boeungkok II, Khan Tuolkok. Phnom Penh, **Cambodia** | Tel : (855-23) 362 913,880 942 |
| 2 | **Hatthakaksekar**<br>Road 4, Peal Ngek I village,Phteash Prey,Sampovmeas District,Pursat Province,50m from highway 5. | Tel: (052) 95144<br>Fax: (052) 951404<br>E-mail: kaksekar@camitel.Com |
| 3 | **Cambodia Micro finance Limited Company**<br># 78Eo,Mao Tse Tong Blvd, Sangkat Boeung Keng Kang III, Chamka Mon, Cambodia. | Tel: (023) 362885 |

## REPRESENTATIVE OFFICE

| | | |
|---|---|---|
| 1 | **STANDARD CRARTERED**<br># Hotel Micasa, Cambodia. | Tel: 426685, 212732 |




អាជ្ញាប័ណ្ណត្រូវបានបន្តរយៈពេល ៣ឆ្នាំម្តង

| ធនាគារ សាខា | ចំនួនសាខា | ធនាគារបានបិទ ២១ | ថ្ងៃ_ខែ_ឆ្នាំដកហូត |
|---|---|---|---|
| (១) បាត់ដំបង. សៀមរាប ( ក្រុងព្រះសីហនុបានបិទនៅថ្ងៃទី ២២ មករា ២០០១ ) | ២ | ធនាគារឥណទានកម្ពុជាត្រូវបានដកហូតអាជ្ញាប័ណ្ណ | ០៦-ឧសភា-៩៥ |
| (២) ក្រុងព្រះសីហនុ. អូឡាំពិក. បាត់ដំបង. កំពង់ចាម. ក្រុងប៉ៃលិន. ហ្សាដឺហ្គូល. សៀមរាប. បិយប៉ែត . កំពត | ៩ | ធនាគារអភិវឌ្ឍន៍កម្ពុជា សុំជំរះបញ្ជីដោយស្ម័គ្រចិត្ត | ២៤-មិថុនា-៩៦ |
| (៣) ម៉ៅសេទុង.និងមុនីរ៉េត. សៀមរាប. ក្រុងព្រះសីហនុ | ៣ | ធនាគារកម្ពុជា រ៉ូយ៉ាល់ សុំជំរះបញ្ជីដោយស្ម័គ្រចិត្ត | ១៩៩៦ |
| (៤) ក្រុងព្រះសីហនុ. សៀមរាប. បាត់ដំបង | ៣ | ធនាគារក្រុងបិទ | ០៤-មេសា-៩៨ |
| (៥) ធនាគាររអេស៊ីលីដា : សាខាខេត្ត | ១៤ | ធនាគារនគរហ្លួងថៃសាខាភ្នំពេញបញ្ឈប់សកម្មភាព | ០១-វិច្ឆិកា-៩៨ |
| (៦) សៀមរាប | ១ | ធនាគារលីពប៉ូសាខាភ្នំពេញបញ្ឈប់សកម្មភាព | ២៥-មិថុនា-៩៩ |
| សរុប | ៣២ | ធនាគារសាជីវកម្មចាន់សាវ៉ាន់វង្ស ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ៣១-កក្កដា-០០ |
| | | ធនាគារកម្ពុជាអន្តរជាតិ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ៣១-កក្កដា-០០ |
| | | ធនាគារកសិករកម្ពុជា (ជំរះបញ្ជីតាមបញ្ជា) | ៣១-កក្កដា-០០ |
| | | ធនាគារ អង្គរ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ៣១-កក្កដា-០០ |
| | | ធនាគារ សកលពាណិជ្ជ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| | | វិសាលធនាគារ អន្តរជាតិ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| | | ធនាគារ សន្តិភាពពាណិជ្ជ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| | | ធនាគារបូរីភ្នំពេញ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| | | ធនាគារ បាងកកសាខាភ្នំពេញ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត ) | ០៨-ធ្នូ-០០ |
| | | ធនាគាររីជំណែស៊្សិណ (ជំរះបញ្ជីតាមបញ្ជា) | ០៨-ធ្នូ-០០ |
| | | ធនាគារពាណិជ្ជកម្ម-កសិកម្មនៃកម្ពុជា (ជំរះបញ្ជីតាមបញ្ជា) | ០៨-ធ្នូ-០០ |
| | | ធនាគារ កសិករថៃមហាជនចំកាត់សាខាភ្នំពេញ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត ) | ៣០-មីនា-០១ |
| | | ធនាគារ ក្រៅប្រទេសទីមួយ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត ) | ១៩-មីនា-០២ |
| | | ធនាគារ សិង្ហបូរីពាណិជ្ជ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត ) | ១៩-មីនា-០២ |
| | | ធនាគារ អ័មគីរីអន្តរជាតិ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត ) | ០៤-មេសា-០២ |

# THE BANKING SYSTEM IN CAMBODIA

*As at July 01 , 2002*

**NATIONAL BANK OF CAMBODIA (CENTRAL BANK)**

- **14 Commercial Banks**
  - 1State owned
    - Foreign Trade Bank
  - 4 Foreign Branch Banks
    - Credit Agricole Indosuez
    - First Commercial Bank
    - Krung Thai Bank
    - May Bank
  - 9 Locally incorporated
    - Advanced of Asia Bank
    - Cambodia Asia Bank
    - Canadia Bank Ltd. (2)
    - Cambodian Commercial Bank (1) (Siam Commercial Bank)
    - Cambodia Mekong Bank (3)
    - Cambodian Public Bank (6) (Public Berhard Bank)
    - Singapore Banking Corporation
    - Union Commercial Bank (4)
    - Vattanac Bank
- **4 Specialized Banks**
  - 1 State owned
    - Rural Development Bank
  - 3 Privately owned
    - ACLEDA Bank limited (5)
    - Peng Heng S.M.E Limited
    - Cambodia agriculture Industrial specialized bank
- **Representative Office**
  - Standard Chartered
- **Micro Finance Institutions**
  - Licensed
    - Enatien MoulethanTchonnebat ( EMT )
    - Hatthakaksekar
    - Microfinance Cambodia
  - Not yet licensed
  - NGOs
    - Registered
      - Khemara
      - Cambodia rural economic development organization
      - Seilanithih
      - Social development in rural
      - Cambodia community building
      - Catholic relief service
      - Cambodia health committee
      - World relief Cambodia
      - Buddhism for development
      - Prasac Credit Association
    - Unregistered
      - Around 60 NGOs
- **20 NBC Provincial Branches**
  - Kampong cham
  - Sihanouk Ville
  - Siemreap
  - Kandal
  - Battambang
  - Prey Veng
  - Kampong thom
  - TaKeo
  - Svay rieng
  - Pursath
  - Kampong chnaing
  - Kampong speu
  - Kampot
  - Koh kong
  - Preah vihear
  - Kratie
  - Ratanakiri
  - Mondolkiri
  - Stung treng
  - Bunteay meanchey
- **Exchange Bureau**
  - Registered 2294
    - Phnom Penh 379
    - Provincial 1.915

License is to be renewed every 3 years.

| BANK BRANCHES | No of Branch | CLOSED BANKS 21 | Dated of withdrawal |
|---|---|---|---|
| (1) Battambang, Siemreap, (Sihanouk Ville closed 22-Jan-01) | 2 | Credit Bank of Cambodia license withdrawn | 06-May-95 |
| (2) Sihanouk Ville, Olimpic, Battambang, Kampong Cham, Pailin, Kampot Charle Degaule, Siemreap, Poipet | 9 | Cambodia development Bank voluntary liquidation | 24-Jun-96 |
| (3) MaoTseTung & Monireth Blvd, Siemreap, Sihanouk Ville | 3 | Royal Cambodia bank voluntary liquidation | 1996 |
| (4) Sihanouk ville, Siemreap, Battambang. | 3 | Municipal Bank closed | 04-Apr-98 |
| (5) ACLEDA Bank: Provincial branches | 14 | Siam City Bank P.Penh branch ceased operation | 01-Nov-98 |
| (6) Siemreap | 01 | P.T.Lippo Bank P.Penh branch ceased operation | 25-Jun-99 |
| **Total** | **32** | Chansavangwonk Bank Corporation (Voluntary liquidated) | 31-Jul-00 |
| | | Cambodia bank International (Voluntary liquidated) | 31-Jul-00 |
| | | Cambodia Farmers Bank (Compulsory liquidated) | 31-Jul-00 |
| | | Angkor Bank (Voluntary liquidated) | 31-Jul-00 |
| | | Global Commercial Bank (Voluntary liquidated) | 08-Dec-00 |
| | | Great International Bank Ltd. (Voluntary liquidated) | 08-Dec-00 |
| | | Pacific Commercial bank Ltd. (Voluntary liquidated) | 08-Dec-00 |
| | | Phnom Penh City Bank (Voluntary liquidated) | 08-Dec-00 |
| | | Bangkok Bank Public Co.Ltd. P.P branch (Voluntary liquidated) | 08-Dec-00 |
| | | Rich Nation Bank (Compulsory liquidated) | 08-Dec-00 |
| | | Agriculture-Commercial bank (Compulsory liquidated) | 08-Dec-00 |
| | | Thai Farmers B.Public Co.Ltd.P.P branch (Voluntary liquidated) | 30-Mar-01 |
| | | First Overseas Bank Compulsory liquidated | 19-Mar-02 |
| | | Singapore Commercial Bank Voluntary liquidated | 19-Mar-02 |
| | | Emperor International Bank Voluntary liquidated | 04-Apr-02 |

# ពីអត្រាប្តូរប្រាក់ថេរទៅអត្រាប្តូរប្រាក់អណ្តែត

ប្រសិនបើអ្នកប្តូរធនប័ត្ររបស់អ្នកទៅជារូបិយវត្ថុមួយផ្សេងទៀត អ្នកនឹងទទួលបាននូវក្រដាសប្រាក់ ឬកាសមួយចំនួន ប៉ុន្តែចំនួននេះអាចប្រែប្រួលរៀងរាល់ថ្ងៃ ឬច្រើនដងក្នុងមួយថ្ងៃ ។ ព្រោះហេតុអ្វី ?

កិច្ចព្រមព្រៀង Bretton Woods ឆ្នាំ ១៩៤៤ បានបង្កើតអត្រាប្តូរប្រាក់ថេរដែលកំណត់ដោយមាស និងដុល្លារអាមេរិក ។ នៅចន្លោះឆ្នាំ ១៩៤៤ និង ១៩៧១ រូបិយវត្ថុជាច្រើនត្រូវបានកំណត់ភ្ជាប់ទៅនឹងដុល្លារអាមេរិក មានន័យថា យុគភាពរបស់រូបិយវត្ថុទាំងនោះជាមួយនឹងដុល្លារអាមេរិកគឺថេរ ។ ក្នុងអំឡុងពេលនេះ ដុល្លារអាមេរិកគឺជាប័ណ្ណសន្យាសងប្រាក់ដែលក្រសួងហិរញ្ញវត្ថុរបស់សហរដ្ឋបានចេញផ្សាយ ។ ប្រសិនបើមាននរណាម្នាក់សំណូមពរប្តូរ ក្រសួងហិរញ្ញវត្ថុត្រូវប្តូរជាមួយប័ណ្ណសន្យាសងប្រាក់នោះនូវមាសចំនួន ១/៣៥ នៃ ounce សំរាប់មួយដុល្លារ ។ នៅក្រោមប្រព័ន្ធនេះ ការកែតំរូវអំពីការឡើងថ្លៃ ឬចុះថ្លៃរបស់រូបិយវត្ថុ ត្រូវតែបានទទួលការយល់ព្រមពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ក្រោមការវាយតម្លៃថារូបិយវត្ថុមានតម្លៃ ។ កំណែតំរូវនោះហៅថាការបញ្ចុះតំលៃ និងការវាយតម្លៃឡើងវិញ ។ ប្រព័ន្ធស្តង់ដារមាស Bretton Woods និងការកំណត់ភ្ជាប់នឹងដុល្លារត្រូវបានគេបោះបង់ចោលនៅក្នុងឆ្នាំ១៩៧១ ដោយសារអតិផរណាជាបន្តបន្ទាប់ ធនាគារបំរុងសហព័ន្ធពុំមានមាសគ្រប់គ្រាន់ដើម្បីធានារូបិយវត្ថុរបស់អាមេរិក ។

ស្តង់ដារប្តូរមាសត្រូវបានជំនួសដោយប្រព័ន្ធអត្រាប្តូរប្រាក់អណ្តែត ។ សព្វថ្ងៃនេះ ដុល្លារអាមេរិកដែលជារូបិយវត្ថុពិភពលោកក្រៅផ្លូវការ គ្រាន់តែជាក្រដាសសាមញ្ញមួយសន្លឹក មានចារឹកអក្សរថា 'In God We Trust.' God, not gold! "យើងជឿជាក់លើព្រះ ។ ព្រះមិនមែនជាមាស!" ។ អត្រាប្តូរប្រាក់អណ្តែតសេរីត្រូវបានកំណត់យ៉ាងពិតប្រាកដដោយការផ្គត់ផ្គង់និងតំរូវការ ។ តាមទ្រឹស្តី នៅពេលមិនមានការកេងយកចំណេញ (Speculation) អត្រាប្តូរប្រាក់ត្រូវឆ្លុះបញ្ចាំងនូវយុគភាពនៃអំណាចទិញ ជាថ្លៃរបស់ទំនិញនិងសេវាកម្មដែលមាននៅក្នុងប្រទេសខុស១គ្នា ។ អ្នកគាំទ្ររបបអត្រាប្តូរប្រាក់អណ្តែត ដែលជាអាទិ៍មានលោក Milton Friedman បានបញ្ជាក់ថា រូបិយវត្ថុទាំងឡាយបានបង្កើតអត្រាប្តូរប្រាក់ស្ថេរជាស្វ័យប្រវត្តិដែលនឹងឆ្លុះបញ្ចាំងភាពពិតនៃសេដ្ឋកិច្ចបានប្រាកដប្រជា ជាងការគណនារបស់មន្ត្រីធនាគារកណ្តាល ។ មន្ត្រីធនាគារកណ្តាលតែងតែប៉ាន់ស្មានមិនបានគ្រប់គ្រាន់នៅឡើយនូវផលប៉ះពាល់នៃការកេងយកចំណេញ និងការរត់តាមនិន្នាការទីផ្សាររូបិយវត្ថុរយៈពេលខ្លីរបស់បណ្តាក្រុមហ៊ុន និងវិនិយោគិន ទោះបីជានិន្នាការទាំងនេះ ផ្ទុយទៅនឹងផលប្រយោជន៍រយៈពេលវែងរបស់ខ្លួនក៏ដោយ ។ នៅចុងទសវត្សទី៧០ និងដើមទសវត្សទី៨០ រដ្ឋាភិបាលអាមេរិក អង់គ្លេស និងរដ្ឋាភិបាលផ្សេងទៀត បានធ្វើបដិប្បញ្ញត្តិនូវប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួន ហើយបានលុបបំបាត់ចោលការត្រួតពិនិត្យការប្តូរប្រាក់ទាំងអស់ ។ ឥឡូវនេះ និវាសជននៅក្នុងប្រទេសទាំងនេះ មាន

លទ្ធភាពប្តូររូបិយវត្ថុរបស់ខ្លួនទៅជារូបិយប័ណ្ណផ្សេងទៀតតាមចំនួនដោយគ្មានកំណត់ ។ ដូច្នេះហើយបានជានាំមកនូវស្ថានភាពបច្ចុប្បន្នដែល ៩៥% នៃប្រតិបត្តិការរបស់សកលលោកទាំងមូលមិនប៉ះពាល់ផ្ទាល់ជាមួយនឹងទំនិញទេ តែពាក់ព័ន្ធសុទ្ធសាធទៅនឹងការកេងយកចំណេញ ។ បរិមាណរូបិយវត្ថុដ៏ច្រើនសម្បើមធ្វើចលនាជុំវិញពិភពលោកដើម្បីដេញតាមអត្រាការប្រាក់ខ្ពស់ឬចំណេញដើមទុន ព្រមពេលដែលវិនិយោគិនទាំងឡាយរួមមានទាំងឯកត្តជន ស្តុកស្តម្ភផង ក្រុមហ៊ុនទាំងឡាយ និងមូលនិធិសោធនស្វះស្វែងធ្វើយ៉ាងណាឱ្យតំលៃទ្រព្យសកម្មរបស់ខ្លួនកើតឡើងជាអតិបរមា ។ ក្នុងទីក្រុងឡុងដុងតែមួយ ចំនួនរូបិយវត្ថុច្រើនជាង៣០០ពាន់លានដុល្លារ ត្រូវបានធ្វើចលនាទិញលក់ជាមធ្យមក្នុងមួយថ្ងៃ (ស្មើនឹងប្រហែល៣០% នៃតំលៃទំនិញដែលប្រទេសអង់គ្លេសផលិតក្នុងមួយឆ្នាំ) ។ ធនាគាររកបានប្រាក់ចំណេញតាមរយៈគម្លាតរវាងថ្លៃទិញនិងថ្លៃលក់រូបិយវត្ថុ ។

ប៉ុន្តែ រដ្ឋាភិបាលមួយចំនួនទុកឱ្យអត្រាប្តូរប្រាក់ទទួលឥទ្ធិពលពីកំលាំងទីផ្សារទាំងស្រុង ។ ភាគច្រើននៃរដ្ឋាភិបាលទាំងនោះគ្រាន់តែព្យាយាមធ្វើអន្តរាគមន៍ទៅលើកំរិតរូបិយវត្ថុរបស់ខ្លួន នៅពេលណាចាំបាច់ប៉ុណ្ណោះ ។ អត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង មានលក្ខណៈទូទៅជាងអត្រាប្តូរប្រាក់អណ្តែតដោយសេរី ។ នៅឆ្នាំ១៩៧៩ រដ្ឋាភិបាលអឺរ៉ុបខាងលិចស្ទើរតែទាំងអស់បានចូលរួមក្នុងយន្តការអត្រាប្តូរប្រាក់ (ERM: Exchange Rate Mechanism) ។ យន្តការនេះបានបង្កើតឡើងនូវយុគភាពរវាងរូបិយវត្ថុរបស់សមាជិកដោយរក្សាគម្លាតលើឬក្រោម ២,២៥% ។ ប្រសិនបើ អត្រាប្តូរប្រាក់ប្រែប្រួលខុសគ្នាឃ្លាតចេញពីគម្លាតនេះ រដ្ឋាភិបាលនិងធនាគារកណ្តាលត្រូវតែធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់ ទិញឬលក់ ដើម្បីបង្កើនឬបន្ថយតំលៃរូបិយវត្ថុរបស់ខ្លួន ។

គោលនយោបាយរបស់រដ្ឋាភិបាលនៅតែអាចត្រូវផ្ទាញ់យ៉ាងងាយស្រួលដោយសកម្មភាពរួមរបស់អ្នកកេងយកចំណេញអន្តរជាតិ ។ ឧទាហរណ៍ គ្រាន់តែមួយថ្ងៃគត់ក្នុងខែកញ្ញា ឆ្នាំ១៩៩២ ធនាគារកណ្តាលអង់គ្លេសបានបង់ខាតអស់ចំនួន ៥ពាន់លានផោន ដោយសារតែប៉ុនប៉ងទាំងអស់សង្ឃឹមក្នុងការទ្រទ្រង់ប្រាក់ pound sterling ។ ក្នុងរយៈពេលច្រើនសប្តាហ៍ ស្ថាប័នហិរញ្ញវត្ថុនិងឯកត្តជនស្តុកស្តម្ភក្នុងពិភពលោកបានលក់ប្រាក់ផោនរបស់ខ្លួនគ្រប់គ្នាទាំងអស់ ដោយគេជឿថា ចាប់តាំងពីចូលរួមក្នុង ERM នៅឆ្នាំ១៩៩០ មកប្រាក់ផោនមានតំលៃលើសយ៉ាងខ្លាំងលើកលែងតែរដ្ឋាភិបាលអង់គ្លេសប៉ុណ្ណោះ ។ នៅពេលដែលធនាគារកណ្តាលអង់គ្លេសចាយស្ទើរតែអស់នូវទុនបំរុងរបស់ខ្លួន ហើយមិនអាចទិញប្រាក់ផោនតទៅទៀតបាន រូបិយវត្ថុត្រូវបានដកចេញពី ERM ហើយទុកឱ្យអណ្តែត ។ ភ្លាមៗនោះមានការបាត់បង់ប្រហែល១៥% នៃតំលៃរបស់វាធៀបនឹងប្រាក់ D-Mark ។ នៅឆ្នាំបន្ទាប់ អ្នកកេងយកចំណេញបានប្រយុទ្ធនឹង French Franc, Belgian Franc, Danish Krone និង Spanish Peseta ។ នៅខែសីហា ឆ្នាំ១៩៩៣ ប្រព័ន្ធរូបិយវត្ថុអឺរ៉ុបត្រូវទទួល

នូវអសកម្មភាពដោយអន្លើ ។ ម្ចាស់កម្មន្តសាលជាច្រើនមានចំណូលចិត្តលើអត្រាប្តូរប្រាក់ថេរ ឬរូបិយវត្ថុរួម ។ ទោះបីជាវាមានលទ្ធភាពខ្លះៗក្នុងការទប់ទល់ការឡើងចុះនៃរូបិយវត្ថុតាមវិធីនៃកិច្ចសន្យាអនាគតក៏ដោយ ក៏គេយល់ថា ការធ្វើផែនការអនាគតគឺជាការលំបាក នៅពេលដែលថ្លៃវត្ថុធាតុដើមនាំចូលមកពីបរទេសឬថ្លៃផលិតផលរបស់អ្នកនាំចេញក្នុងស្រុកអាចកើនឡើងឬធ្លាក់ចុះដល់ ៥០% តែក្នុងរយៈពេលពីរ ឬបីខែប៉ុណ្ណោះ ។ (ចាប់តាំងពីការត្រួតពិនិត្យអត្រាប្តូរប្រាក់ត្រូវបានលុបចោលមក រូបិយវត្ថុទាំងឡាយដែលរួមទាំងដុល្លារអាមេរិក និងផោនអង់គ្លេស បានគ្រលប់ជាឡើងថ្លៃរហូតដល់១០០% ហើយក្រោយមកក៏ចុះថ្លៃវិញលើសពី ៥០% ធៀបនឹងរូបិយវត្ថុនៃប្រទេសជាដៃគូពាណិជ្ជកម្មធំៗ) ។ អ្នកគាំទ្រអត្រាប្តូរប្រាក់ថេរ ឬរូបិយវត្ថុរួមផ្សេងទៀត មានរួមបញ្ចូលផងដែរនូវអ្នកអភិរក្សជ្រុលដែលចង់ត្រឡប់ទៅរកស្តង់ដារមាសវិញ ក៏ដូចជាអ្នកទាំងឡាយដែលជឿថា អ្នកកេងយកចំណេញមានអំណាចច្រើនបំផុត។ អ្នកគាំទ្រអត្រាអណ្តែតរួមមានទាំងអ្នករូបិយវត្ថុនិយមដែលចង់ឱ្យប្រទេសទាំងឡាយគោរពតាមវិធានរូបិយវត្ថុតឹងរ៉ឹង ក៏ដូចជាអ្នកនិយម Keynesians ដែលចង់ឱ្យការបញ្ចុះថ្លៃរូបិយវត្ថុប្រព្រឹត្តទៅដោយសេរី ក្នុងគោលបំណងដើម្បីកាត់បន្ថយភាពគ្មានការងារធ្វើ ។ ទាំងនេះហាក់ដូចជាសម្ព័ន្ធភាពគួរភ្ញាក់ផ្អើលដែលបង្កើតឱ្យមានការសង្ស័យចំពោះកាលវិភាគសំរាប់ផែនការដាក់ឱ្យប្រើប្រាស់នូវរូបិយវត្ថុអឺរ៉ុបរួម ។

## ការរួមចំណែករបស់ធនាគារជាតិនៃកម្ពុជាក្នុងការងារកែទំរង់ប្រព័ន្ធពន្ធដារ

ការបង់ពន្ធគឺជាកាតព្វកិច្ចរបស់ពលរដ្ឋ ។ ពលរដ្ឋមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ ដើម្បីរដ្ឋមានប្រភពចំណូលសំរាប់ចំណាយសេវាសាធារណៈ ។ ប្រទេសដែលរីកចំរើន គឺអាស្រ័យដោយមានប្រព័ន្ធពន្ធដារប្រកបដោយប្រសិទ្ធភាព ធ្វើអោយរដ្ឋាភិបាលទទួលបានចំណូលពីប្រាក់ពន្ធ បង្កើនជាប្រាក់សន្សំ និងអាចវិនិយោគទៀតផង ។ ប្រព័ន្ធពន្ធដារប្រកបដោយប្រសិទ្ធភាព គឺអាស្រ័យដោយប្រជាពលរដ្ឋមានជំនឿ និងទំនុកចិត្តថាប្រាក់កាតព្វកិច្ចរបស់គេពិតជាត្រូវបានរដ្ឋប្រើប្រាស់ជាគុណប្រយោជន៍ចំពោះប្រទេសជាតិ ។ យ៉ាងណាមិញសេដ្ឋកិច្ចកម្ពុជាក៏ត្រូវពឹងផ្អែកមួយផ្នែកធំលើប្រភពចំណូលពន្ធដារនេះដែរ ។

រាជរដ្ឋាភិបាលកម្ពុជាបានលើកកម្មវិធីកំណែទំរង់ម៉ាក្រូសេដ្ឋកិច្ច កំណែទំរង់រចនាសម្ព័ន្ធដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ជាពិសេសកំណែទំរង់ស្ថិរភាវូបនីយកម្មសេដ្ឋកិច្ចជាទិសដៅចំបងជាយុទ្ធសាស្ត្រ ។ កិច្ចអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុពឹងផ្អែកយ៉ាងខ្លាំងលើកំណែទំរង់អភិបាលកិច្ច ដែលចំពោះមុខគឺការពង្រឹងការទទួលខុសត្រូវរបស់បណ្តាស្ថាប័ននៅក្នុងវិស័យសាធារណៈ ។

អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធនាគារជាតិនៃកម្ពុជាបានខិតខំប្រឹងប្រែងអនុវត្តកំណែទំរង់ប្រព័ន្ធធនាគារនិងប្រព័ន្ធប្រមូលថវិការដ្ឋ ដោយបាននិងកំពុងពិនិត្យឡើងវិញអំពីរចនាសម្ព័ន្ធ និងវិធីសាស្ត្រកែលំអនយោបាយរូបិយវត្ថុ បង្កើនអភិបាលកិច្ចល្អក្នុងសកម្មភាពរបស់ខ្លួនសំដៅអោយសំរេចបាននូវគោលដៅខាងលើ ។

ថ្ងៃទី ២៦ តុលា ឆ្នាំ ២០០១ ក្រសួងសេដ្ឋកិច្ចនិងហិញ្ញវត្ថុបានចេញប្រកាសលេខ ៧៩៥ សហវ-ពដ ស្តីពីបែបបទនៃការបង់ប្រាក់ពន្ធសំរាប់អ្នកជាប់ពន្ធធំ ។ គោលដៅនៃប្រកាសគឺអ្នកជាប់ពន្ធធំដែលជាអាជីវករមានផលរបរប្រចាំឆ្នាំចាប់ពី មួយពាន់លានរៀល ឡើងទៅត្រូវបង់ពន្ធដោយផ្ទាល់ចូល ក្នុងគណនីរបស់នាយកដ្ឋានពន្ធដារដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ។

ធនាគារជាតិនៃកម្ពុជា រតនាគារជាតិ និងនាយកដ្ឋានពន្ធដារបានជួបពិភាក្សាគ្នាជាច្រើនលើក ដើម្បីកំណត់នូវនីតិវិធីបច្ចេកទេសនិងការងារផ្សេងៗមួយចំនួនទៀតដើម្បីធានាអោយដំណើរការការងារមានភាពរលូន និងទទួលបានលទ្ធផលល្អប្រសើរ ។

### នីតិវិធីនៃការបង់ពន្ធដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា

នាយកដ្ឋានពន្ធដារបើកគណនីចរន្តជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានប្រតិបត្តិការ) ដែលអ្នកជាប់ពន្ធធំអាចមកបង់ពន្ធដោយផ្ទាល់ ក្រោមរូបភាពជាសាច់ប្រាក់ឬជាមូលប្បទានបត្រ ។

## ការបង់ពន្ធជាសាច់ប្រាក់

អ្នកជាប់ពន្ធត្រូវមកបង់ដោយផ្ទាល់នៅបញ្ជរបេឡាធនាគារជាតិនៃកម្ពុជា រួចយកប័ណ្ណបង់ប្រាក់មកនាយកដ្ឋានប្រតិបត្តិការ ដើម្បីចុះបញ្ចូលទឹកប្រាក់ដែលបានបង់ពន្ធទៅក្នុងគណនីរបស់នាយកដ្ឋានពន្ធដារ ។ ប័ណ្ណបង់ប្រាក់គឺជាសក្ខីប័ត្រដែលអ្នកជាប់ពន្ធត្រូវយកទៅបង្ហាញនិងប្រគល់ជូននាយកដ្ឋានពន្ធដារជាភស្តុតាងថាបានបង់ប្រាក់រួច ។



សកម្មភាពអតិថិជនចូលបង់ពន្ធជាសាច់ប្រាក់( រៀល និងដុល្លារ) ឬជាមូលប្បទានប័ត្រ
នៅបញ្ជរធនាគារជាតិនៃកម្ពុជា ។

## ការបង់ពន្ធជាមូលប្បទានប័ត្រ

អ្នកជាប់ពន្ធដែលមានគណនីនៅធនាគារពាណិជ្ជណាមួយក្នុងទីក្រុងភ្នំពេញអាចចេញមូលប្បទានប័ត្រដើម្បីបង់ពន្ធជាប្រាក់រៀលឬប្រាក់ដុល្លារអាមេរិក ។ មូលប្បទានប័ត្រត្រូវយកមកប្រគល់អោយនាយកដ្ឋានប្រតិបត្តិការនឹងត្រូវបានទទួលត្រឡប់វិញនូវបង្កាន់ដៃទទួលមូលប្បទានប័ត្រសំរាប់ទុកមកប្តូរយកប្រកាសឥណទានក្រោយពីមូលប្បទានប័ត្រនោះត្រូវបានទូទាត់ឆ្លងតាមរយៈសភាផាត់ទាត់បញ្ចូលប្រាក់ក្នុងគណនីរបស់នាយកដ្ឋានពន្ធដាររួច ។

មូលប្បទានប័ត្រប្រគល់ជូននាយកដ្ឋានប្រតិបត្តិការមុនម៉ោង ៩.០០ ព្រឹក ត្រូវបានបញ្ជូនទៅសភាផាត់ទាត់នាគ្រាផាត់ទាត់ក្នុងថ្ងៃ ។

មូលប្បទានប័ត្រប្រគល់ជូននាយកដ្ឋានប្រតិបត្តិការក្រោយម៉ោង ៩.០០ ព្រឹកត្រូវបានរក្សាទុក និង បញ្ជូនទៅសភាផាត់ទាត់នាគ្រាផាត់ទាត់ថ្ងៃធ្វើការបន្ទាប់ ។

ចំណូលពន្ធជាប្រាក់ដុល្លារអាមេរិកត្រូវបានចុះចូលគណនីចរន្តជាដុល្លារអាមេរិក ដោយនៅចុងថ្ងៃនីមួយៗត្រូវផ្ទេរប្តូរជាប្រាក់រៀលតាមអត្រាប្តូរប្រាក់មធ្យមផ្លូវការ រួចបង្វែរចូលគណនីចរន្តជាប្រាក់រៀលរបស់នាយកដ្ឋានពន្ធដារ ។

ផ្អែកតាមលិខិតលេខ ១៤៤០ ពដ ចុះថ្ងៃទី ១៣-១២-២០០១ របស់នាយកដ្ឋានពន្ធដារ ធនាគារជាតិនៃកម្ពុជា មានសិទ្ធិផ្ទេរប្រាក់ពីគណនីចរន្តរបស់នាយកដ្ឋានពន្ធដារទៅគណនីរបស់រតនាគារជាតិនៅចុងថ្ងៃនីមួយៗ ។

រតនាគារជាតិមានលទ្ធភាពបើកសាច់ប្រាក់ពីធនាគារជាតិនៃកម្ពុជាបានជាប្រចាំ និងជាប្រភេទប្រាក់ល្អដែលបានធ្វើការស្រាល់ជ្រើសរួចជាស្រេច ។

ការងារទទួលចំណូលពន្ធដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរដោយមានកិច្ចសហការល្អរវាងនាយកដ្ឋានពន្ធដារ អគ្គបេឡា រតនាគារជាតិ ។ អតិថិជនដែលជាអ្នកបង់ពន្ធចាប់ផ្តើមមានទំលាប់ចេញចូលបង់ពន្ធដោយផ្ទាល់តាមកាលកំណត់របស់នាយកដ្ឋានពន្ធដារ ភាគច្រើនចន្លោះពីថ្ងៃទី១០ ទៅថ្ងៃទី២០ នៃខែនីមួយៗ ។

ការអនុវត្តន៍ ចំណូលពន្ធដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា ដែលជាអ្នកគ្រប់គ្រងថែរក្សាគណនីរបស់នាយកដ្ឋាពន្ធដារ ជាបច្ច័យល្អក្នុងការកែទំរង់រចនាសម្ព័ន្ធប្រមូលចំណូលថវិការដ្ឋអោយកាន់តែមានភាពល្អប្រសើរឡើង និងអាចឈានទៅអនុវត្តចំពោះបណ្តាខ្ទង់ចំណូលថវិការដ្ឋផ្សេងៗទៀតនាពេលអនាគតខាងមុខ។

# ទំនាក់ទំនងហិរញ្ញវត្ថុរវាងប្រទេសកម្ពុជានិងមូលនិធិរូបិយវត្ថុអន្តរជាតិ

ប្រទេសកម្ពុជាបានចូលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅថ្ងៃទី៣១ ធ្នូ ឆ្នាំ១៩៦៩ ដោយបានបង់កូតា (Quota) ដំបូងចំនួន ២៥លាន SDR ។ បន្ទាប់ពីមានការផ្អាកសហប្រតិបត្តិការមួយរយៈ ដោយសារមានជំលោះក្នុង ស្រុកដែលផ្តើមឡើងនៅទសវត្សទី៧០ ធនាគារជាតិនៃកម្ពុជានិង IMF បាន ចាប់ផ្តើមធ្វើការទំនាក់ទំនងជិតស្និទ្ធឡើងវិញជាមួយនឹងការផ្តល់ឥណទានកំណែទំរង់រចនាសម្ព័ន្ធ (Structural Transformation Facilities-STF ) នៅថ្ងៃទី៧ ខែ តុលា ឆ្នាំ ១៩៩៣ មានចំនួន ៦,២៥ លាន SDR (ចំនួនទឹកប្រាក់ត្រូវបានដកប្រើប្រាស់គ្រប់ចំនួន) និងការផ្តល់ឥណទានកែតំរូវរចនាសម្ព័ន្ធ (Enhanced Structural Adjustment Facility-ESAF) នាឆ្នាំ ១៩៩៤ ចំនួន ៨៤ លាន SDR ដោយក្នុងនោះបានដកយក មកប្រើប្រាស់ចំនួន៣លើក ÷

- ការដកប្រើប្រាស់លើកទី១ : ចំនួន ១៤ លាន SDR នៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៤
- ការដកប្រើប្រាស់លើកទី២ : ចំនួន ១៤ លាន SDR នៅថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៥
- ការដកប្រើប្រាស់លើកទី៣ : ចំនួន ១៤ លាន SDR នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

សរុបទឹកប្រាក់ដែលបានដកប្រើប្រាស់មានចំនួន ៤២ លាន SDR ប្រមាណជា ៦០ លានដុល្លារអាមេរិក ដូច្នេះទឹកប្រាក់ដែលពុំបានប្រើនៅក្នុងឥណទាន ESAF នោះគឺ ៥០% នៃទឹកប្រាក់ដែលបានសន្យាផ្តល់សរុប ។



កិច្ចជំនួបរវាងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ជាមួយក្រុមការងារមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៩ ដើម្បីគាំទ្រការងារកែទំរង់សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ បានអនុម័តកិច្ចព្រមព្រៀងលើឥណទានកាត់បន្ថយភាពក្រីក្រ និងបង្កើនកំណើនសេដ្ឋកិច្ច (PRGF) សំរាប់រយៈពេល ៣ ឆ្នាំ (១៩៩៩-២០០២) ដែលមានទឹកប្រាក់ចំនួន ៥៨,៥ លាន SDR (ប្រមាណ៧៨,៥លានដុល្លារអាមេរិក) ដើម្បីទ្រទ្រង់កម្មវិធីកែទំរង់សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ឆ្នាំ១៩៩៩-២០០២ ដោយក្នុងនោះបានដកយកមកប្រើប្រាស់ចំនួន៥លើកដូចតទៅ ÷

- ការដកប្រើប្រាស់លើកទី ១ : ចំនួន ៨,៣៥៧ លាន SDR នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៩
- ការដកប្រើប្រាស់លើកទី ២ : ចំនួន ៨,៣៥ លាន SDR នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០
- ការដកប្រើប្រាស់លើកទី ៣ : ចំនួន ៨,៣៥៦ លាន SDR នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០១
- ការដកប្រើប្រាស់លើកទី ៤ : ចំនួន ៨,៣៥៧ លាន SDR នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១
- ការដកប្រើប្រាស់លើកទី ៥ : ចំនួន ៨,៣៥៧ លាន SDR នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២
- ការដកប្រើប្រាស់លើកទី ៥ : ចំនួន ៨,៤ លាន SDR នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០២

ដូច្នេះ សរុបមកដល់ពេលនេះទឹកប្រាក់ចំនួន ៥០,១ លាន SDR (ប្រមាណ ៦៧,៣លានដុល្លារអាមេរិក) បានដកមកប្រើប្រាស់ ហើយនៅសល់ចំនួន ៨,៤ លាន SDR ទៀត ធនាគារជាតិនៃកម្ពុជាសង្ឃឹមថានឹងបានបើកយកមកប្រើប្រាស់នៅក្នុងខែកុម្ភៈ ដើមឆ្នាំ ២០០៣ ទៅតាមកម្មវិធីដែលបានគ្រោងទុក ។

ឥណទានកាត់បន្ថយភាពក្រីក្រ និងបង្កើតកំណើនសេដ្ឋកិច្ច (PRGF) មានលក្ខណៈសម្បត្តិ៣យ៉ាងសំខាន់ៗ ប្លែកពីឥណទាន ESAF គឺ ÷

- ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលទៅលើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលទាមទារនូវការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍ ។
- ការកាត់បន្ថយភាពក្រីក្រ ត្រូវបានកំណត់ជាចំណុចផ្តោតយ៉ាងសំខាន់នៃឯកសារ និង
- ភាពជាដៃគូ ដែលទាមទារឱ្យរាជរដ្ឋាភិបាលបង្កើន និងពង្រឹងសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នផ្សេងៗ ទាំងក្នុងនិងក្រៅប្រទេស ជាពិសេសជាមួយវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ។ល។ សំដៅសំរេចនូវគោលដៅរួមគឺ លើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

ក្នុងនាមជាធនាគារកណ្តាល ធនាគារជាតិនៃកម្ពុជាមានតួនាទីជាអ្នកសំរបសំរួល និងជាដៃគូសហប្រតិបត្តិការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ការផ្សារភ្ជាប់ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិមានសារៈសំខាន់ជាខ្លាំងចំពោះមុខមាត់នយោបាយរបស់កម្ពុជាលើឆាកអន្តរជាតិ ព្រោះទំនាក់ទំនងល្អបានផ្តល់ជាសញ្ញាវិជ្ជមានដល់សហគមន៍អន្តរជាតិថា កម្ពុជាមានគោលនយោបាយអភិវឌ្ឍន៍ប្រទេសមួយគួរជាទី

ទុកចិត្តពីសំណាក់អន្តរជាតិ និងវិនិយោគិនបរទេស ។

ទេសាភិបាលរបស់ប្រទេសកម្ពុជាប្រចាំ IMF គឺទេសាភិបាលធនាគារជាតិនៃកម្ពុជា និងទេសាភិ-បាលរងប្រចាំ IMF គឺទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ។

នាយកប្រតិបត្តិរបស់ IMF ទទួលបន្ទុកតំណាងបណ្តាសមាជិក IMF នៅអាស៊ីអាគ្នេយ៍ គឺលោក Dono Iskanda Kjojosubroto ជនជាតិឥណ្ឌូនេស៊ី ដែលមានអណត្តិពីខែ ១១-២០០-ខែ១០-២០០២ ។

លើមូលដ្ឋាននៃការពិនិត្យលើកូតាឡើងវិញនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើនកូតា (Quota) របស់ព្រះរាជាណាចក្រកម្ពុជាក្នុងមូលនិធិរូបិយវត្ថុអន្តរជាតិចំនួន២លើក ÷

**លើកទី១ :** បង្កើនពី ២៥ លាន SDR ដល់ ៦៥លាន SDR នៅលើមូលដ្ឋាននៃការពិនិត្យលើកូតាឡើងវិញលើកទី ៩ (Ninth General Review of Quotas) ក្នុងឆ្នាំ ១៩៩៤ ។

**លើកទី២ :** បង្កើនពី ៦៥ លានSDR ដល់ ៨៧.៥ លាន SDR នៅលើមូលដ្ឋាននៃការពិនិត្យលើកូតាឡើងវិញលើកទី ១១ (Eleventh General Review of Quotas) ក្នុងខែកុម្ភៈ ឆ្នាំ១៩៩៩ ។

ដូច្នេះ កូតារបស់ប្រទេសកម្ពុជានៅក្នុង IMF បច្ចុប្បន្នមានចំនួន ៨៧.៥ លាន SDR ( Special Drawing Right) គឺប្រមាណជា ១២២.៥ លានដុល្លារអាមេរិក គឺស្មើ 0.0៥% នៃសំលេងឆ្នោតសរុបនៅក្នុង IMF ។

ជាមួយនឹងការផ្តល់នូវជំនួយជាហិរញ្ញវត្ថុ មូលនិធិរូបិយវត្ថុអន្តរជាតិនៅតែបន្តផ្តល់ជំនួយបច្ចេកទេសជាបន្តបន្ទាប់ដើម្បីបំពាក់បំប៉ននូវចំណេះដឹងដល់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា លើមុខវិជ្ជាជំនាញជាច្រើន ជាពិសេសផ្នែកត្រួតពិនិត្យធនាគារ គណនេយ្យជាតិ ជញ្ជីងទូទាត់ និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ ។ ដោយឡែកនៅក្នុងការធ្វើកំណែទំរង់ប្រព័ន្ធធនាគារ បេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិក៏បានផ្តល់នូវបទពិសោធន៍ និងការណែនាំផ្សេងៗជាច្រើន ដែលមានផលប្រយោជន៍ក្នុងដំណើរការអនុវត្តន៍ការផ្តល់អាជ្ញាប័ណ្ណជាថ្មីដល់បណ្តាធនាគារពាណិជ្ជ ។

## ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

## ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសំរាប់ឆ្នាំ២០០១-២០១០

### សេចក្តីសង្ខេប

នៅក្រោមបរិដ្ឋានសេដ្ឋកិច្ចសង្គមនិងគតិយុត្តបច្ចុប្បន្ន កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា គឺជាការប្រឈមមមួយចំពោះរាជរដ្ឋាភិបាល ក៏ដូចជាចំពោះវិស័យឯកជនផងដែរ ។ ទោះបីជាកិច្ចប្រឹងប្រែង ទាំងនេះត្រូវបានធ្វើឡើងនៅក្នុងមុខព្រួញជាច្រើនក្តី ក៏រាជរដ្ឋាភិបាលមានទស្សនៈថាប្រទេសកម្ពុជាចាំបាច់ ត្រូវប្រកាន់យកនូវកិច្ចប្រឹងប្រែង ដែលមានលក្ខណៈផ្សារភ្ជាប់គ្នា និងដែលមានលក្ខណៈជាប្រព័ន្ធដើម្បី អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំមួយផ្អែកលើមូលដ្ឋានទីផ្សារ ដើម្បីគាំទ្រការកៀងគរធនធាន និងគាំទ្រកំណើន សេដ្ឋកិច្ចដ៏មាននិរន្តរភាពដែលផ្អែកលើមូលដ្ឋានដ៏ទូលំទូលាយ ។

ជាមួយនឹងគោលដៅទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បានបង្កើតឡើងនូវចក្ខុវិស័យ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងសំរាប់វិស័យហិរញ្ញវត្ថុ ។ ចក្ខុវិស័យ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល វែងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើមេរៀនជាគន្លឹះ ដែលដកស្រង់មកពីបទពិសោធន៍នៃប្រទេសអាស៊ី ដទៃទៀតនៅក្នុងកិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក៏ដូចជាបានមកពីសភាពការណ៍បច្ចុប្បន្ននៅប្រទេសកម្ពុជា ។ រដ្ឋាភិបាលកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ីដែលបាន សហការយ៉ាង ជិតស្និទ្ធ និងផ្តល់នូវជំនួយបច្ចេកទេសចាំបាច់ក្នុងការរៀបចំឯកសារដ៏មានសារៈសំខាន់នេះ ។

### ចក្ខុវិស័យនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង

កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុផ្អែកយ៉ាងខ្លាំងលើកំណែទំរង់អភិបាលកិច្ច ។ បញ្ហាលំបាកមួយនៃបញ្ហា លំបាកសំខាន់ៗទាំងឡាយដែលស្ថិតនៅចំពោះមុខប្រទេសកម្ពុជានៅក្នុងវិស័យអភិបាលកិច្ចនោះ គឺការពង្រឹង ការទទួលខុសត្រូវរបស់បណ្តាស្ថាប័ននៅក្នុងវិស័យសាធារណៈ ។ ក្នុងចំណោមកំណែទំរង់ទាំងឡាយ កំណែ ទំរង់ដ៏ចាំបាច់រួមមាន (i) កំណែទំរង់រដ្ឋបាលសាធារណៈ (ii) កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ (iii) កំណែ ទំរង់ច្បាប់និងតុលាការ ។

ប្រសិនបើកម្មវិធីកំណែទំរង់អភិបាលកិច្ចដែលបានលើកឡើងនៅក្នុង **"ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទីពីរ និង ផែនការសកម្មភាពអភិបាលកិច្ច"** ត្រូវបានអនុវត្តយ៉ាងពេញលេញនោះ សេដ្ឋកិច្ចកម្ពុជា រំពឹងថានឹងអាចរក្សាអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំបានពី ៦ ទៅ ៧ភាគរយនៅក្នុងរយៈពេលមធ្យម ខាងមុខ ។

ដោយកសាងលើក្តីរំពឹង នៃកិច្ចអភិវឌ្ឍន៍ដែលនឹងសំរេចបានតាមរយៈកំណែទំរង់អភិបាលកិច្ចប្រកប ដោយជោគជ័យ ផែនការជាយុទ្ធសាស្ត្រនេះប្រមាណទុកជាមុនថា វិស័យហិរញ្ញវត្ថុនឹងកើនឡើងយ៉ាងហោច

ណាស់ពីរដងគិតជាអនុបាតនៃទ្រព្យសកម្មហិរញ្ញវត្ថុធៀបនឹងផលិតផលក្នុងស្រុកសរុបក្នុងរយៈពេលដប់ឆ្នាំ ។ គំលាតរវាងអត្រាការប្រាក់នៃការផ្តល់ឥណទាននិងប្រាក់បញ្ញើនឹងខិតជិតគ្នា នៅពេលដែលអន្តរការិយកម្មកាន់តែមានប្រសិទ្ធភាព ដោយសារមានស្ថេរភាពខាងម៉ាក្រូសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធខាងច្បាប់ និងហិរញ្ញវត្ថុកាន់តែប្រសើរឡើង ហើយការប្រកួតប្រជែងក្នុងចំណោមធនាគារនិងស្ថាប័នហិរញ្ញវត្ថុដទៃទៀតកាន់តែកើនឡើង ។

ចក្ខុវិស័យនេះនឹងអាចត្រូវសំរេចបានដោយអនុវត្តឱ្យបាននូវប្រការខាងក្រោម :

- ប្រព័ន្ធធនាគារមានលក្ខណៈប្រកួតប្រជែង មានសុវត្ថិភាព មានការគ្រប់គ្រងនិងត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងមានការកៀងគរសញ្ច័យយ៉ាងមានប្រសិទ្ធភាពដើម្បីផ្តល់ហិរញ្ញប្បទានគាំទ្រការលូតលាស់នៃផ្នែកឯកជន ។
- ការបង្កើតឡើង និងការអភិវឌ្ឍន៍គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារដែលបង្កើននូវជំរៅនៃវិស័យហិរញ្ញវត្ថុ ដោយផ្តល់នូវសេវាកម្មដ៏សំបូរបែបមានជាអាទិ៍ ភតិសន្យា និងហិរញ្ញប្បទាន ឧបភោគ-បរិភោគ ។
- វិស័យធានារ៉ាប់រងដែលការពារអាជីវកម្ម និងបុគ្គលអំពីព្រឹត្តិការណ៍មហន្តរាយទាំងឡាយ និងផ្តល់ទុនសំរាប់វិនិយោគរយៈពេលវែងនៅក្នុងវិស័យផលិតកម្ម ។
- ប្រព័ន្ធដ៏មានសុវត្ថិភាពនិងគួរឱ្យទុកចិត្តបានសំរាប់ការផ្ទេរមូលនិធិរវាងអតិថិជននិងធនាគារ និងការទូទាត់រវាងធនាគារ ។
- ទីផ្សាររូបិយវត្ថុ និងទីផ្សារអន្តរធនាគារដែលផ្តល់ជូនធនាគារ ក្រុមហ៊ុន និង បុគ្គលនូវមធ្យោបាយសំរាប់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលប្រកបដោយប្រសិទ្ធភាព ។
- ទីផ្សារទុនប្រកបដោយប្រសិទ្ធភាព និងប្រកបដោយតំលាភាព ដែលមានចំនួនអ្នកចេញផ្សាយជាច្រើនដែលកៀងគរមូលនិធិសំរាប់វិនិយោគរយៈពេលវែង ។
- ប្រព័ន្ធច្បាប់មួយដែលជំរុញ និងអនុវត្តវិធានច្បាប់នៅក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងហិរញ្ញវត្ថុដែលគាំទ្រអភិបាលកិច្ចល្អតាមរយៈការបង្កើនតំលាភាព ការទទួលខុសត្រូវ ការចូលរួម និងភាពដែលអាចទស្សន៍ទាយជាមុនបាន ។
- ប្រព័ន្ធគណនេយ្យ និងសវនកម្មមួយដែលផ្អែកលើស្តង់ដារអន្តរជាតិដែលគាំទ្រអភិបាលកិច្ចល្អដោយជំរុញនូវតំលាភាព ការទទួលខុសត្រូវ ការចូលរួម និងភាពអាចទស្សន៍ទាយជាមុនបាន ។

- កិច្ចអភិវឌ្ឍន៍ធនធានមនុស្សដែលឈរលើមូលដ្ឋានប្រាក់បំណាច់ និងការតម្លើងឋានៈដោយផ្អែកលើសមត្ថភាពការងារ និងអត្ថិភាពនៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដ៏ទូលំទូលាយដែលរក្សាទុកនូវបុគ្គលិកមានស្រាប់ និងផ្តល់នូវការបណ្តុះបណ្តាលជាបន្តបន្ទាប់ ។

រដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្ររយៈពេលវែង សំរាប់កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ដែលមានសមាសភាគខាងក្រោម:

- រក្សានយោបាយសារពើពន្ធនិងរូបិយវត្ថុឱ្យបានល្អ ដើម្បីធានាឱ្យបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។
- បង្កើតក្របខ័ណ្ឌច្បាប់ដ៏ល្អមួយ ដើម្បីការពារកម្មសិទ្ធិ និងជំរុញការអនុវត្តន៍កិច្ចសន្យា ។
- បង្កើតវិធានច្បាប់ (The rule of Law) តាមរយៈកំណែទំរង់ច្បាប់ និងកំណែទំរង់តុលាការដើម្បីទ្រទ្រង់សកម្មភាពហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ។
- កំណត់លំដាប់លំដោយនៃការខិតខំប្រឹងប្រែងសំដៅអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ជាពិសេសប្រព័ន្ធទូទាត់និងផាត់ទាត់ ប្រព័ន្ធគណនេយ្យនិងសវនកម្ម ប្រព័ន្ធពត៌មានឥណទាន និងក្របខ័ណ្ឌបទប្បញ្ញត្តិ ។
- កែសំរួលរចនាសម្ព័ន្ធនៃក្របខ័ណ្ឌបទប្បញ្ញត្តិ និងនយោបាយ ដើម្បីជំរុញការប្រកួតប្រជែងនៅក្នុងក្នុងទីផ្សារហិរញ្ញវត្ថុ និងដើម្បីលើកទឹកចិត្តគ្រឹះស្ថានហិរញ្ញវត្ថុឱ្យសំរេចបាននូវសេដ្ឋកិច្ចនៃមាត្រដ្ឋាននិងសេដ្ឋកិច្ចវិសាលភាព (economies of scale and scope) ។
- បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិ និងស្ថាប័នដើម្បីជំរុញឱ្យមានគោលការណ៍អភិបាលកិច្ចល្អ និងដើម្បីអនុញ្ញាតឱ្យវិស័យទីផ្សារមានដំណើរការនៅក្នុងការគ្រប់គ្រងនិងប្រតិបត្តិការនៃគ្រឹះស្ថានហិរញ្ញវត្ថុ ។
- បង្កើតក្របខ័ណ្ឌដ៏ល្អមួយសំរាប់កិច្ចអភិវឌ្ឍន៍ផ្នែកឯកជននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដោយលុបបំបាត់ជាបណ្តើរៗនូវកម្មសិទ្ធិរដ្ឋ និងអន្តរាគមន៍រដ្ឋនៅក្នុងប្រព័ន្ធនេះ ។
- បង្កើតក្របខ័ណ្ឌប្រកបដោយតំលាភាពមួយសំរាប់ការចូលធ្វើអាជីវកម្ម ដើម្បីលើកទឹកចិត្តដល់ប្រសិទ្ធភាព និងការធ្វើឱ្យស៊ីជំរៅវិស័យហិរញ្ញវត្ថុ ។
- បង្កើតយន្តការអនុញ្ញាតឱ្យចាកចេញពីអាជីវកម្មប្រកបដោយប្រសិទ្ធភាពសំរាប់គ្រឹះស្ថានមានបញ្ហា ដើម្បីជំរុញឱ្យមានកំណែលំអររចនាសម្ព័ន្ធឥតឈប់ឈរនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុដោយពុំបណ្តាលមានចំណាយខាងសង្គមឡើយ ។

- អភិវឌ្ឍសមត្ថភាពមនុស្ស និងស្ថាប័នទាំងក្នុងផ្នែកឯកជន និងសាធារណៈតាមរយៈភាពជាដៃគូរវាងផ្នែករដ្ឋ និងផ្នែកឯកជន ។

### ផែនការអភិវឌ្ឍន៍តាមវិស័យ

ស្ថិតនៅក្រោមការណែនាំនៃយុទ្ធសាស្ត្ររយៈពេលវែង ផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រនេះពណ៌នាលំអិតនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងរបៀបវារៈកំណែទំរង់គោលនយោបាយ ។ ផែនការអភិវឌ្ឍន៍តាមវិស័យលើកយកមកពិចារណានូវចំណងទាក់ទងរវាង (i) ការកសាងសមត្ថភាពធនធានមនុស្ស និងសមត្ថភាពស្ថាប័ន (ii) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុពាក់ព័ន្ធ (iii) ការបង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ (iv) ការកើតឡើងនូវទីផ្សារហិរញ្ញវត្ថុពាក់ព័ន្ធ និង (v) វត្តមាននៃបច្ចេកវិទ្យា ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ គឺជាផែនការរំកិលដែលតំរូវឱ្យមានការកែលំអរជាបន្តបន្ទាប់ ដើម្បីឆ្លុះបញ្ចាំងនូវសមិទ្ធផលរបស់រដ្ឋាភិបាល ក៏ដូចជាការប្រែប្រួលបរិដ្ឋានសេដ្ឋកិច្ច-សង្គមកិច្ចផងដែរ ។ រដ្ឋាភិបាលប្តូរផ្តាច់ក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍន៍តាមវិស័យដែលមានចែងនៅក្នុងផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រនេះ ក៏ដូចជាបន្តកែលំអផែនការអភិវឌ្ឍន៍តាមវិស័យនេះជាបន្តបន្ទាប់ ដើម្បីឆ្លុះបញ្ចាំងនូវសមិទ្ធផលរបស់រដ្ឋាភិបាល និងការប្រែប្រួលបរិដ្ឋានសេដ្ឋកិច្ច-សង្គមកិច្ច ហើយតាមរយៈនេះនឹងបង្កើនផលប៉ះពាល់ជាអតិបរមាទៅលើការអភិវឌ្ឍន៍ ។

### វិស័យធនាគារ

ផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រចំពោះវិស័យធនាគាររួមមានបីដំណាក់កាល ។ ដំណាក់កាលទីមួយមានគោលបំណងរៀបចំនូវមូលដ្ឋានគ្រឹះសំរាប់ប្រព័ន្ធធនាគារ ដោយបង្កើតក្របខ័ណ្ឌគោលនយោបាយ និងស្ថាប័នជាមូលដ្ឋាន ។ ដំណាក់កាលទីពីរមានបំណងលើកកំពស់អន្តរការិយកម្មតាមរយៈការប្រកួតប្រជែង ។ ដោយផ្អែកលើសមិទ្ធផលនៅក្នុងដំណាក់កាលទីមួយ ប្រព័ន្ធធនាគារគប្បីត្រូវបានអភិវឌ្ឍឱ្យក្លាយទៅជាប្រព័ន្ធមួយដែលរឹងមាំជាងមុនតាមរយៈការប្រកួតប្រជែងរវាងធនាគារ ហើយអន្តរការិយកម្មនឹងត្រូវបានពង្រីកនៅពេលដែលសេវាធនាគារត្រូវបានពង្រីកទៅកាន់តំបន់ជនបទ ។ ដំណាក់កាលទីបីមានគោលបំណងជំរុញប្រសិទ្ធភាពអន្តរការិយកម្ម តាមរយៈការជួយសំរួលសមាហរណកម្មរវាងវិស័យហិរញ្ញវត្ថុផ្លូវការនិងមិនផ្លូវការ ក៏ដូចជារៀបចំចាត់តាំងឡើងវិញនូវឧស្សាហកម្មធនាគារ ។ វិស័យធនាគារដែលត្រូវបានធ្វើសមាហរណកម្មនឹងពង្រឹងប្រសិទ្ធភាពនិងគុណភាពសេវាធនាគារនៅតំបន់ជនបទ ។

### វិស័យធានារ៉ាប់រងនិងប្រព័ន្ធសោធននិវត្តន៍

ការអភិវឌ្ឍនៃវិស័យធានារ៉ាប់រងក៏ឆ្លងកាត់បីដំណាក់កាលផងដែរ ។ ដើម្បីលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងសមត្ថភាពត្រួតពិនិត្យដ៏ទន់ខ្សោយក្នុងពេលបច្ចុប្បន្ន ដំណាក់កាលទីមួយមានគោលដៅកសាង

មូលដ្ឋានគ្រឹះនិងកសាងសមត្ថភាពចំពោះវិស័យធានារ៉ាប់រង ។ នៅពេលដែលមាន មូលដ្ឋានគ្រឹះរឹងមាំរួច ហើយ វិស័យធានារ៉ាប់រងនឹងរីកចំរើនទាំងទំហំនិងភាពសំបូរបែបរបស់ខ្លួន ។ ការផ្តោតនៅក្នុងដំណាក់កាលទីពីរគឺសំដៅជំរុញទីផ្សារធានារ៉ាប់រងតាមរយៈការអភិវឌ្ឍន៍ផ្នែកឯកជន សំដៅបង្កើនសកម្មភាពឆ្ពោះទៅរកអ្នកក្រីក្រនិងឆ្ពោះទៅតំបន់ជនបទ សំដៅអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច និងសំដៅបង្កើនភាពសំបូរបែបនៃសេវាហិរញ្ញវត្ថុ ។ ការអនុវត្តន៍របបធានារ៉ាប់រងជាកាតព្វកិច្ចនឹងបង្កើតតំរូវការដែលផ្អែកលើគោលនយោបាយ ហើយប្រាក់ចំណូលដែលចេះតែកើនឡើងនឹងបង្កើត តំរូវការចំពោះប្រភេទច្រើនបែបនៃផលិតផលធានារ៉ាប់រង ។ ជាកិច្ចឆ្លើយតបនឹងភាពជឿនលឿននិងបរិមាណដែលចេះតែកើនឡើងនៃការងារអាជីវកម្មនៅក្នុងវិស័យធានារ៉ាប់រង ចាំបាច់ត្រូវបង្កើតស្ថាប័នត្រួតពិនិត្យឯករាជ្យមួយសំរាប់វិស័យធានារ៉ាប់រង ។ ហើយនៅពេលដែលវិស័យធានារ៉ាប់រងមានការរីកចំរើនជាបន្តថែមទៀត ពេលនោះស្ថាប័នត្រួតពិនិត្យវិស័យធានារ៉ាប់រងឯករាជ្យនឹងធ្វើទំនើបកម្មបន្ថែមទៀតនូវបទប្បញ្ញត្តិប្រុងប្រយ័ត្ននៅក្នុង ដំណាក់កាលទីបី ។

នៅក្នុងដំណាក់កាលទីមួយនៃការអភិវឌ្ឍន៍ប្រព័ន្ធសោធននិវត្តន៍ ការសិក្សាអំពីលទ្ធភាពសំរាប់អនុវត្ត និងការរៀបចំគំរោងសំរាប់បង្កើតប្រព័ន្ធសោធននិវត្តន៍ជាច្រើនប្រទេទនោះនឹងត្រូវបានបញ្ចប់ ។ ក្នុងដំណាក់កាលទីពីរ ក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ និងត្រួតពិនិត្យ នឹងត្រូវបានបង្កើតឡើងសំរាប់ប្រព័ន្ធសោធននិវត្តន៍ ។ ជាងនេះទៀត ក៏ចាំបាច់ត្រូវតែមានយន្តការកសាងសមត្ថភាពដើម្បីធានាឱ្យបុគ្គលិកនៃអង្គភាពបញ្ញត្តិករ និងត្រួតពិនិត្យនេះទទួលបាននូវការបណ្តុះបណ្តាលសមស្រប ។ នៅក្នុងដំណាក់កាលទីបី ក្របខ័ណ្ឌគតិយុត្តនេះនឹងត្រូវបានអនុវត្តតាមរយៈការចេញអនុក្រឹត្យនានា ។ កម្មវិធីសោធននិវត្តន៍សាធារណៈជាកាតព្វកិច្ចនឹងត្រូវផ្តួចផ្តើមឡើង ហើយការពង្រឹងបន្ថែមទៀតនូវក្របខ័ណ្ឌត្រួតពិនិត្យ និងបទប្បញ្ញត្តិ នឹងប្រព្រឹត្តទៅ ដោយរំពឹងថានឹងមានការអនុវត្តន៍នូវកម្មវិធីសោធននិវត្តន៍ជាកាតព្វកិច្ចមានមូលនិធិគ្រប់គ្រងដោយឯកជនដែលនឹងកើតមានឡើងបន្ទាប់ពីដំណាក់កាលទីបី ។

### គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ

ការអភិវឌ្ឍន៍គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ (NBFIs) នឹងចាប់ផ្តើមដំណើរការនៅក្នុងដំណាក់កាលទីពីរ ។ គោលដៅនៃការអភិវឌ្ឍន៍គឺដើម្បីផ្តល់ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសំរាប់គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារឱ្យស្របគ្នាជាមួយការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារ ទីផ្សាររូបិយវត្ថុ និងទីផ្សារទុន ។ អាស្រ័យហេតុនេះ គោលដៅរបស់ដំណាក់កាលទីពីរ គឺបង្កើតមូលដ្ឋានគ្រឹះនៃច្បាប់ និងបទប្បញ្ញត្តិ សំរាប់គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដូចជា ក្រុមហ៊ុនភតិសន្យា ក្រុមហ៊ុនហិរញ្ញវត្ថុ ក្រុមហ៊ុនវិនិយោគនិងពាណិជ្ជករ និងជើងសាករទីផ្សាររូបិយវត្ថុ ។ គោលដៅរបស់ដំណាក់កាលទីបី គឺអភិវឌ្ឍគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារបន្ថែមទៀត ដោយរួមបញ្ចូលទាំងក្រុមហ៊ុនអាណត្តិព្យាបាល ក្រុមហ៊ុនបណ្តាក់ទុន (Venture Capital Companies) និងគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍រយៈពេលវែង ។ គ្រឹះស្ថានទាំងនោះនឹងទ្រទ្រង់ការ

អភិវឌ្ឍន៍ទីផ្សាររូបិយវត្ថុ និងទីផ្សារទុន ។

### ទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ

លំដាប់លំដោយនិងល្បឿននៃកិច្ចអភិវឌ្ឍន៍ទីផ្សាររូបិយវត្ថុនឹងត្រូវដើរសម្របតាមកិច្ចអភិវឌ្ឍន៍វិស័យធនាគារនិងវិស័យមិនមែនធនាគារ ។ ផែនការអភិវឌ្ឍន៍សំរាប់ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុមានគោលដៅជាយុទ្ធសាស្ត្របី ។ ដំណាក់កាលទីមួយ មានគោលបំណងបង្កើតមូលដ្ឋានគ្រឹះសំរាប់ទីផ្សារអន្តរធនាគាររយៈពេលខ្លីគ្មានប្រាតិភោគ និងផ្តល់មូលដ្ឋានសំរាប់ទីផ្សាររូបិយវត្ថុ រួមទាំប័ណ្ណរតនាគារដោយផ្អែកលើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងកិច្ចសន្យាទិញយកវិញ ក៏ដូចជាការធើឱ្យការចេញផ្សាយប័ណ្ណរតនាគារមានភាពទៀងទាត់ និងការបង្កើតប្រព័ន្ធជួញដូរបឋម ។ ដំណាក់កាលទីបី សំដៅពង្រីកទីផ្សាររូបិយវត្ថុជាមួយនឹងក្របខ័ណ្ឌបទបញ្ញាសំរាប់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុដែលចេញផ្សាយឧបករណ៍ទីផ្សាររូបិយវត្ថុ ដូចជាផលប័ត្រពាណិជ្ជកម្មជាដើម ។

### ទីផ្សារទុន

ផែនការអភិវឌ្ឍន៍ទីផ្សារទុនរួមមានគោលដៅអភិវឌ្ឍន៍តាមលំដាប់លំដោយចំនួនបី ។ នៅក្នុងដំណាក់កាលទីមួយ រដ្ឋាភិបាលនឹងធ្វើការងារត្រៀមលក្ខណៈជាចាំបាច់ ដើម្បីបង្កើនបរិដ្ឋានអំណោយផលមួយសំរាប់ទីផ្សារទុន ។ នៅក្នុងដំណាក់កាលទីពីរ មូលដ្ឋានគ្រឹះសំរាប់ទីផ្សារទុននឹងត្រូវបង្កើតឡើងតាមរយៈការបង្កើតទីផ្សារមូលប័ត្រព្រមទាំហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដែលពាក់ព័ន្ធនឹងការជួញដូរមូលប័ត្រ ក៏ដូចជាការអនុមតិបទប្បញ្ញត្តិ និងនីតិវិធីលំអិត ។ ផ្អែកលើការងារត្រៀមលក្ខណៈនៅដំណាក់កាលទីពីរនោះ រដ្ឋាភិបាលនឹងត្រូវខំប្រឹងប្រែងជាខ្សែសង្វាក់ដើម្បីអភិវឌ្ឍទីផ្សារទុននៅដំណាក់កាលទីបី ។

### ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ

#### ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធច្បាប់

ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធច្បាប់សំរាប់ទីផ្សារហិរញ្ញវត្ថុក៏ផ្តោតទៅរករបៀបវារៈកំណែទំរង់បីនៅក្នុងរយៈពេលដប់ឆ្នាំខាងមុខនេះដែរ ។ គោលដៅនៅក្នុងដំណាក់កាលទីមួយ គឺដាក់ចេញនូវច្បាប់សំខាន់ៗដែលទាក់ទងនឹងសកម្មភាពពាណិជ្ជកម្មដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។ នៅក្នុងដំណាក់កាលទីពីរ ការអនុវត្តន៍ច្បាប់នឹងត្រូវបានពង្រឹងដោយមានការជឿនលឿននៅក្នុងកំណែទំរង់តុលាការនិងការកសាងសមត្ថភាព ។ ដំណាក់កាលទីបីនឹងផ្តោតលើការលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធច្បាប់សំរាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ។ នៅក្នុងដំណាក់កាលនេះ ក្របខ័ណ្ឌច្បាប់សំរាប់ប្រព័ន្ធចុះបញ្ជីសាធារណៈចំពោះចលនទ្រព្យនឹងត្រូវបានបង្កើត ។

### ការអភិវឌ្ឍន៍ប្រព័ន្ធគណនេយ្យនិងសវនកម្ម

ប្រព័ន្ធគណនេយ្យនិងសវនកម្មគឺជាគ្រឹះសំរាប់កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ហើយកំពុងទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ ។ គោលដៅនៅក្នុងដំណាក់កាលទីមួយគឺដើម្បីបង្កើតស្តង់ដារគណនេយ្យនិងសវនកម្ម និងប្រព័ន្ធមួយសំរាប់ជំរុញការអនុវត្តន៍ស្តង់ដារទាំងនេះ តាមរយៈការប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសាជីវកម្ម សវនកម្មនៃគណនេយ្យនេះ និងវិជ្ជាជីវៈគណនេយ្យ តាមរយៈការអនុមតិស្តង់ដារគណនេយ្យអន្តរជាតិ និងស្តង់ដារសវនកម្មអន្តរជាតិ និងការបង្កើតអង្គភាពវិជ្ជាជីវៈគណនេយ្យមួយ និងក្រុមប្រឹក្សាស្តង់ដារគណនេយ្យមួយ ។ នៅក្នុងដំណាក់កាលទីពីរ សមាគមគណនេយ្យនឹងពង្រឹងការជំរុញនៃការអនុវត្តន៍ស្តង់ដារគណនេយ្យនិងស្តង់ដារសវនកម្ម និងជំរុញការប្រកួតប្រជែងនៅក្នុងឧស្សាហកម្មគណនេយ្យដើម្បីកាត់បន្ថយថ្លៃចំណាយលើការអនុវត្តន៍ផ្នែកគណនេយ្យនិងសវនកម្មរបស់ផ្នែកឯកជន ។ នៅក្នុងដំណាក់កាលទីបី នឹងកើតមានការជំរុញនៃការអនុវត្តន៍ស្តង់ដារគណនេយ្យនិងការពង្រីកស្តង់ដារគណនេយ្យទៅកាន់សហគ្រាសទាំងឡាយ ។

### ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធពត៌មានហិរញ្ញវត្ថុ

ដើម្បីមានអន្តរការិយកម្មហិរញ្ញវត្ថុដ៏មានប្រសិទ្ធភាព កិច្ចអភិវឌ្ឍន៍ប្រព័ន្ធពតិមានហិរញ្ញវត្ថុមានតួនាទីដ៏សំខាន់ក្នុងការបណ្តុះវប្បធម៌ឥណទាន និងការទូទាត់សងនៅក្នុងដំណាក់កាលដំបូងនៃកិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។ នៅក្នុងដំណាក់កាលទីមួយ រដ្ឋាភិបាលនឹងបង្កើតប្រព័ន្ធពតិមានទីផ្សារហិរញ្ញវត្ថុតាមរយៈដំណើរការផ្លាស់ប្តូរពតិមានឥណទានដែលដឹកនាំដោយធនាគារិក ។ នៅក្នុងដំណាក់កាលទីពីរ រដ្ឋាភិបាលនឹងពង្រីកវិសាលភាពនៃដំណើរការទៅដល់គ្រឹះស្ថានមិនមែនធនាគារ ។ នៅក្នុងដំណាក់កាលទីបី ប្រព័ន្ធពតិមានទីផ្សារហិរញ្ញវត្ថុនឹងកាន់តែត្រូវបានធ្វើឱ្យមានភាពសំបូរបែបបន្ថែមទៀត តាមរយៈការរួមបញ្ចូលនូវឧស្សាហកម្មធ្វើចំណាត់ថ្នាក់ឥណទាន ។

### ការអភិវឌ្ឍន៍បណ្តាញសុវត្ថិភាពវិស័យហិរញ្ញវត្ថុ

បណ្តាញសុវត្ថិភាពវិស័យហិរញ្ញវត្ថុនឹងត្រូវអភិវឌ្ឍ ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធហិរញ្ញវត្ថុ ។ នៅពេលដែលប្រព័ន្ធហិរញ្ញវត្ថុរីកចំរើន ហានិភ័យជាប្រព័ន្ធក៏កើនឡើងដែរ ។ កិច្ចអភិវឌ្ឍន៍បណ្តាញសុវត្ថិភាពហិរញ្ញវត្ថុរួមមាន របៀបវារៈកំណែទំរង់ពីរដំណាក់កាល ដែលចាប់ផ្តើមពីដំណាក់កាលទីពីរ ។ គោលដៅនៃដំណាក់កាលទីពីរ គឺសំដៅអភិវឌ្ឍបណ្តាញសុវត្ថិភាពវិស័យធនាគារជាមួយនឹងការបង្កើតឡើងនូវការធានារ៉ាប់រងប្រាក់បញ្ញើនិងការណែនាំស្តីពីអភិបាលកិច្ចសាជីវកម្ម ។ ដំណាក់កាលទីបីនឹងពង្រីកការធានារ៉ាប់រងប្រាក់បញ្ញើទៅដល់អ្នកចូលរួមនៃវិស័យមិនមែនធនាគារ ដែលរួមចំណែកក្នុងប្រព័ន្ធទូទាត់ ។

ការអនុវត្តន៍ផែនការជាយុទ្ធសាស្ត្រនេះប្រកបដោយជោគជ័យ គឺអាស្រ័យលើការដឹកនាំដ៏រឹងមាំ ការប្តេជ្ញាដ៏ម៉ឺងម៉ាត់ និងកិច្ចប្រឹងប្រែងដ៏ធំធេងរបស់រដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងធនាគារជាតិនៃកម្ពុជា ។ ផែនការនេះក៏អំពាវនាវផងដែរឱ្យមានការគាំទ្រពីផ្នែកឯកជន និងជំនួយ ដ៏ទាន់ពេលវេលារបស់អ្នកផ្តល់ជំនួយអន្តរជាតិ ពីព្រោះការចូលរួមដ៏សកម្មរបស់ផ្នែកឯកជន និងអ្នកផ្តល់ជំនួយអន្តរជាតិ គឺជាប្រភពដែលពុំអាចខ្វះបាននៃការផ្តល់ចំណេះដឹងសំរាប់ការអនុវត្តន៍ផែនការជាយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យ ។

# សហប្រតិបត្តិការអន្តរជាតិទ្វេភាគី



ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី រវាងធនាគាររដ្ឋវៀតណាម និងធនាគារជាតិនៃកម្ពុជា-ភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១




ពិធីបើកកិច្ចប្រជុំទ្វេភាគីរវាងធនាគារកណ្តាលថៃ និងធនាគារជាតិនៃកម្ពុជា -ភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០២

# សកម្មភាពសង្គមកិច្ចរបស់ធនាគារជាតិនៃកម្ពុជា



សកម្មភាពចែកអំណោយដល់ប្រជាពលរដ្ឋ របស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា





សកម្មភាពចែកអំណោយដល់ប្រជាពលរដ្ឋ របស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា





សកម្មភាពពិគ្រោះជម្ងឺជូនមន្ត្រី បុគ្គលិកនៅគិលានដ្ឋានធនាគារជាតិនៃកម្ពុជា ។



សកម្មភាពពិនិត្យជម្ងឺជូនមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ។



សកម្មភាពអាហារដ្ឋានធនាគារជាតិនៃកម្ពុជា ក្នុងការបំរើអាហារថ្ងៃត្រង់ជូនមន្ត្រីបុគ្គលិក ។



# ចំណុចសំគាល់មួយចំនួនស្តីពីប្រាក់ដុល្លារក្លែងក្លាយ

**1. Genuine** : Microprinting of the letter "USA" and number "100" are in the middle of security line.

**Counterfeit** : Microprinting of letters "USA" and number "100" are not in middle of security line.

**Genuine**




**Cunterfeit**




**2. Genuine** : Water-mark of portrait appears symmetrical and rich in details.

**Counterfeit** : Water-mark of portrait appears symmetrical in form and sparse in details.

**Genuine**




**Cunterfeit**



**3. Genuine** : Colour shifting ink is darker in colour.

**Counterfeit :** Colour shifting ink is lighter in colour.

**Genuine**




**Counterfeit**




**4. Genuine** : The portrait looks lighter ahd slimmer.

**Counterfeit :** The portrait looks darker and swollen.

**Genuine**



**Counterfeit**



5. **Genuine** : White colour net type of strip lines appears as square pattern when view against light.

**Counterfeit** : White colour net type of strip lines appears triagular prism when viewed against light.

**Genuine**




**Counterfeit**




6. **Genuine** : Edge on the lower left part of the lamp post is thinner with less definition.

**Counterfeit** : Edge on the lower left part of the lamp post is more pronounced and thick.

**Genuine**




**Counterfeit**



7. **Genuine** : Righht side of tree trunk is darker.

**Counterfeit :** Right side of tree trunk is lighter.

**Genuine**




**Counterfeit**

